

ROYAUME DU CAMBODGE
REGIE
DEPOT LEGAL

B-8
D-37
N° 151

ក.67

415

គិត-ហារិន

▼

# ឧបករណ៍អនុពាក្យ

# LES ÉLÉMENTS DE DICTÉE

ARCHIVES NATIONALES
COTE 6/261

សំរាប់

ការសិក្សាគ្រប់ថ្នាក់

ការផ្សាយរបស់

បណ្ណាគារ ឌុច-ឈីង

លេខ ៨៨ រុក្ខវិថីឧកញ៉ាភ្លុង ផ្សារចាស់

ភ្នំពេញ

រក្សាសិទ្ធិ

# អាទិកថា

កាលនៅកំពុងសិក្សា ខ្ញុំតែងបានជួបប្រទះជាញឹកញយនូវកិច្ចកលក្នុងអនុពាក្យខ្មែរ ដែលនាំឲ្យអ្នកសិក្សាខ្វះវង្វេង, ប្រឡំ, ខុសស្មើរឥតលស់ខាន ៗ ការពើបពះនេះ បង្កើតទៅជាគំនុំមួយត្រៀមនៅក្នុងចិត្តរបស់ខ្ញុំជានិច្ច ដើម្បីនឹងដេញតាមកំចាត់នូវកិច្ចកលទាំងនោះឲ្យបាន ៗ ដោយទេសៈកាលៈនេះ កម្មវិធីសិក្សាអក្សរសាស្ត្រជាតិបានរត់កាត់ទម្លាយកំពែងធំ ៗ ចូលទៅតាំងទីជាស្ថាពរនៅគ្រប់គ្រឹះស្ថានសិក្សាជាតិ ហើយកំពុងមានសកម្មភាពយ៉ាងរវើកទៀតផង, ឱកាសឈប់សម្រាកប្រចាំឆ្នាំក្នុងឆ្នាំ ១៩៥៩នេះ នាំឲ្យខ្ញុំនឹកឃើញគំនុំរបស់ខ្ញុំចំពោះកិច្ចកលនោះឡើងវិញ ។ កិច្ចកលនេះបើរកវិធីកំចាត់មិនឃើញទេ មុខជាវានឹងស្ដែងមាយាដាក់អ្នកសិក្សារឹតតែខ្លាំងឡើង ៗ ទើបខ្ញុំរៀបរៀងវិធីកំចាត់ទាំង

នោះដាក់ជាមួយក្រុមឲ្យឈ្មោះថា «ឧបករណ៍អនុពាក្យ» នេះឡើង ដើម្បីជាគ្រឿងប្រដាប់សម្រាប់ជួយឧបត្ថម្ភដល់អ្នកសិក្សាក្នុងការតបទនឹងកិច្ចការអនុពាក្យ ។ «ឧបករណ៍អនុពាក្យ» ពុំមែនជាមេរៀនត្រូវចាំមាត់ទេ តែជាមេគំនិតមួយដែលជាមិត្តដ៏ប្រសើររបស់អ្នកសិក្សាអនុពាក្យខ្មែរ ។

ភ្នំពេញ, ថ្ងៃទី ៨ កក្កដា ឆ្នាំ ១៩៥៩

ភិន-ហ៊ាន

# ការសរសេរអនុពាក្យ

ការសរសេរអនុពាក្យ ពុំមែនសំដៅទៅលើអក្សរល្អ មិនល្អ ឬសរសេរឲ្យគ្រាន់តែមើលកើត ដូចជាការសរសេរព្រាងនោះទេ គឺសំដៅលើលក្ខណៈច្បាស់ផ្ចិតផ្ចង់ ស្អាតបាតមានស្ថានភាពនៃដៃជើងតួអក្សរត្រឹមត្រូវ មិនឃ្លៀងឃ្លាតពីអក្ខរវិធី ពីព្រោះការសរសេរក្នុងពេលនេះមានគ្រូ ឬមេប្រយោគច្រើនរូបជាអ្នកចាំពិនិត្យ រកចាប់កំហុសរបស់យើង ៗ អ្នកចាប់ពិរុទ្ធ មិនមែនសម្លឹងមើលតែពាក្យខុសត្រូវប៉ុណ្ណោះទេ គេពិនិត្យមើលសព្វគ្រប់ទាំងតួព្យញ្ជនៈ ស្រៈជើងជើងនៃការសរសេររបស់យើង ៗ បើកាលណាយើងសរសេរមិនច្បាស់ ដាក់ដៃជើងមិនត្រូវតាមស្ថានភាពនៃលក្ខណៈអក្សរសាស្ត្រខ្មែរនោះ មុខជាយើងទឹងត្រូវអ្នកកែប្រមិចប្រមោចយកកំហុសអស់ជាច្រើន ផ្សំទឹងអក្ខរាវិរុទ្ធទៀត ៗ

ដូច្នេះ មុននឹងចាប់សរសេរអនុវាក្យ គប្បីអ្នកសិក្សា ហាត់សរសេរអក្សរខ្មែរ ឲ្យបានជាទម្លាប់ត្រឹមត្រូវពិតប្រាកដ មែនទែនជាដរាប ។ ទម្លាប់ពិតប្រាកដរបស់យើង នឹងបាន ទទួលលទ្ធផលយ៉ាងគាប់ប្រសើរ ដែលអាចឲ្យយើងទុកចិត្ត ខ្លួនឯងកាន់តែវិសេសឡើង ។

១– ចូរប្រយ័ត្នតួព្យញ្ជនៈទាំងនេះ កុំសរសេរឲ្យ ប្រឡំគ្នា ក-គ-ត-ក, ដ-ជ-ថ-ផ, ប-ម-ឞ, ឆ-ធ-, រ-វ, ល-ស, ហ-មា, ង-ឯ ។

២– ចូរសរសេរស្រៈនឹងជើងទាំងនេះឲ្យច្បាស់ ។

ស្រៈ ួ កុំឲ្យប្រឡំជើង ្ឈ (ជើង ្ឈ កួបជួបគ្នា)

ស្រៈ ូ ” ្យ (ជើង ្យ កួបជួបគ្នា)

ស្រៈ ឹ ” ៊ (ស្រៈ ៊ មានបន្តក់)

ជើង ច្យ “ ឡ (ជើង ្យ-កួបក្បាលចេញក្រៅ)

ជើង ឡ កុំឲ្យច្រឡំជើងយ (ជើង ្យ ក្បាលចូលក្នុង)

ជើង ្ថ    "    ្ល (ជើង ្ល ចុងឡើងលើ) ។

៣ – ចូរប្រយ័ត្នក្នុងផ្ញើជើងនឹងស្រះ ា ។

ព្យញ្ជនៈណាដែមានផ្ញើជើង ហើយដាក់ស្រះ ា ផង (ខ្លា) មិនត្រូវសរសេរផ្ញើជើងទៅខាងក្រោមស្រះ (ខ្លូ) ទេ ពីព្រោះមិនមានស្រះណាមួយ អាចមានផ្ញើជើងទេ មានតែតួព្យញ្ជនៈទើបផ្ញើជើងបាន ។

។. ខ្លា, ឆ្មា, អាត្មា ។ល។ មិនត្រូវសរសេរជាខ្លូ, ឆ្មូ, អាត្មូ ដូច្នេះទេ ។

# ការអានអនុពាក្យ

យើងសង្កេតឃើញថា ក្នុងបណ្ដាសិស្ស ឬបេក្ខជនមួយថ្នាក់ ៗ តែងមានសមត្ថភាពពីរពួក ។ ពួកទី ១ ជាអ្នកមានសតិល្អតែយល់ច្បាស់នូវអត្ថន័យនៃពាក្យ ហើយចេះចាំពាក្យ-ស័ព្ទជាច្រើនផង ។ ពួកនេះបើទុកជាអ្នកអាន ៗ ប្រឡំពាក្យ ឬបន្ទុំយ៉ាងណាក៏នៅតែសរសេរត្រូវដែរ ។ ពួកទី ២ ជាអ្នកមានសតិខ្សោយ មិនសូវចាំពាក្យអក្ខរាវិរុទ្ធ ហើយមិនយល់អត្ថន័យរបស់ពាក្យ ។ ពួកនេះកាលណាអ្នកអានប្រឡំសូរស័ព្ទបន្តិចបន្តួច ក៏មិនអាចជៀសវាងកំហុសបានមួយឡើយ ហើយតែងត្អូញត្អែរថា អានមិនច្បាស់-មិនត្រូវ ។ តើអ្នកអានត្រូវនិយមតាមពួកណា ?

ម្យ៉ាងទៀត ដោយប្រទេសនីមួយ ៗ តែងមានជនបទនៅដាច់សន្វែងពីគ្នា ឬ ដោយមាននិគមជនបទខ្លះតាំងនៅជាយដែនខុងកាត់មាត់ញក ពាក់ចង់ប្រឡូកប្រឡល់តែនឹង

ភាសាបរទេសនោះ, ក្នុងប្រទេសខ្មែរយើងសង្កេតឃើញថា អ្នកស្រុកភូមិភាគកណ្តាលដូរតាមមាត់ទន្លេក្នុង ដូចជាស្រុកល្វាឯមជាដើម ច្រើននិយាយស្រៈអើប្រែទៅ ជាអែ (ដើម ជាដែម), ស្រៈអឿប្រែទៅជា អា (ទៀនជាតាន) ។ អ្នកស្រុកបាត់ដំបងភាគខ្លះ និយាយស្រៈអោ ប្រែទៅ អូ (គោ ជា គូ) ។ អ្នកស្រុកសៀមរាប, ក្រចេះនិងលើកដែកភាគខ្លះ និយាយស្រៈអិ ប្រែទៅជាអួ (មាន់គក ជាមាន់គួក) ។ អ្នកស្រុកក្រចេះនឹងកំពង់ចាមភាគខ្លះ និយាយបំបាត់តួព្យញ្ជនៈពេលអស់ (ស្វាម្ដុំពោរគោបម៍ជ្វា ជា ឡាលូពោគោបម៍រ៉ា) ។ អ្នកស្រុកតាកែវភាគខ្លះ និយាយជើងដ្ត ប្រែទៅជាជើង ឌ (កណ្តាល ជា កណ្ឌាល) ។ អ្នកស្រុកព្រៃវែងភាគខ្លះ និយាយស្រៈអាប្រែទៅជាអែ (តាញ ជាតែញ) ។ល។

ទោះបីមានការផ្សេងគ្នាដោយសមត្ថភាពនឹងដោយការទម្លាប់និយាយដូច្នេះក៏ដោយ អ្នកអានត្រូវតែនិយមករណីយ-

កិច្ចរបស់ខ្លួនទៅតាមក្បួនអក្ខរវិធី ជាមូលដ្ឋាន ។ អ្នកអានត្រូវតែអានឲ្យច្បាស់ ៗ មានឃ្លាល្បះ មិនលឿនពេកមិនញាប់ពេក ហើយពាក្យនីមួយត្រូវអាននិយមតាមតែអក្ខរវិធីនឹង វិធីអានប៉ុណ្ណោះ មិនត្រូវនិយមតាមភាសានិយាយសាមញ្ញ ឬ តាមទម្លាប់អ្នកស្រុកនីមួយ ៗ នោះទេ ព្រោះការអានពាក្យសរសេរតាមសូត្រនេះ ពុំមែនជាការនិយាយពាក្យសាមញ្ញជួបសំដីក្នុងផ្លូវនោះទេ គឺជាសូរស័ព្ទមានលក្ខណ: មានក្បួនច្បាប់ទៀងទាត់តាមក្បួនអក្ខរវិធីមួយ ដែលមានសិស្ស ឬ បេក្ខជនជាច្រើននាក់នៅចាំស្ដាប់ប្រុងនឹងសរសេរតាមសំឡេង ។ ព្រោះហេតុនោះទើបការអានជាលក្ខណ: ចាំបាច់សម្រាប់អ្នកសិក្សា ។

## ការអានខ្ទះក្នុងភាសាខ្មែរ

តាមអក្ខរវិធី, ក្នុងភាសាខ្មែរយើងមានសំឡេងពីរ គឺ អឃោសៈនឹងឃោសៈ ។ ព្យញ្ជនៈដែលមានសំឡេងមិន

គឹកកង ហៅថា អឃោសៈមាន ១១ តួគឺ កខ, ចឆ, ដឋ, តថ, បផ, ស ។ ព្យញ្ជនៈដែលមានសូរគឹកកងហៅថា ឃោសៈ មាន ២១ តួគឺ គឃង, ជឈញ, ឌឍណ, ទធន, ពភម, យរលវ ហឡ ។

ព្យញ្ជនៈនៅចុងវគ្គ ៥ តួគឺ ង, ញ, ណ, ន, ម ហៅថា វគ្គន្តៈ ។ ព្យញ្ជនៈនៅសល់ពីវគ្គ ៦ តួគឺ យ, រ, ល, វ, ហឡ ហៅថា សេសវគ្គ ។

ចំពោះពាក្យពីព្យាង្គ, កាលណាមានព្យញ្ជនៈជាអ-ឃោសៈនៅជាប់ខាងដើម, ព្យញ្ជនៈជាវគ្គន្តៈនឹងសេសវគ្គនេះ ត្រូវប្រែសំឡេងដើមរបស់ខ្លួនលំអោនទៅតាមព្យញ្ជនៈអឃោសៈវិញ៖

| | |
|---|---|
| ក្រមា (ក្រម៉ា) | ខមាទោស (ខៈម៉ា.ទោស) |
| ចលនា (ចៈឡៈណា) | ឆាយា (ឆា.យ៉ា) |
| ដកម (ដ.ក៉ម) | ឋានៈ (ឋា-នៈ) |

តម្រា (ដំ.រ៉ា)   ថេរៈ (ថេ.រ៉ៈ)

ប្រមាញ់ (ប្រម៉ាញ់)   ផលា (ផៈ.ឡា)

សង្ការ (សង់ ក៉ារ)   ស្រក់ (ស្រ.ក៉) ។ល។

លើកលែងតែពាក្យខាងក្រោមនេះ ដែលគណៈកម្មការវប្បធម៌សន្មតឲ្យអានតាមសម្រួល ៖

ស្ថានីយ ឲ្យអានថា (ស្ថា-នីយ) មិនឲ្យអានថា ស្ថា.ណីយ-ទេ

ខែមីនា „ (ខែ-មីណា) „ មីនា-ទេ

សម្តេចព្រះមហាក្សត្រិយានី ឲ្យអានថា (ក្រិយ៉ា.នី) មិនឲ្យអានថា យ៉ា.ណីទេ ។

មានព្យញ្ជនៈ ១៧ តួគឺ កខគឃ, ចឆជឈ, ដឋឌឍ, តថទធ, ស បើទុកជាមានព្យញ្ជនៈដទៃនៅជាប់ខាងដើមក៏មិនអាចដួលសំឡេងស្របទៅតាមបានដែរ ៖

ក.និកាយ (មិនអាចជា និគាយទេ) ខ.សង្ខារ (មិនអាចជាសង្ឃារទេ)

គ.សង្គម ( „ ស័ង-ក័មទេ) ឃ.សង្ឃឹម ( „ ស័ង-ខឹមទេ)

ច. វិចារ (មិនអាចវិជារទេ) ឆ. គូឆាយ (មិនអាចគូ.ឈាយទេ)

ជ. បញ្ជី ( „ បញ្ចីទេ ) ឈ. បញ្ឈរ ( „ បញ្ចរទេ)

ដ. ពិដោរ ( „ ពិឌោរទេ) ឋ. ពាឋា ( „ ពា-ធាទេ )

ឌ. បណ្ឌិត ( „ បណ្ដិតទេ) ឍ. អឌ្ឍៈ ( „ អឍ្ឍៈទេ )

ត. ជតា ( „ ជៈតាទេ ) ថ. ពូថៅ ( „ ពូធៅទេ)

ទ. បន្ទាត់ ( „ បន្តាត់ទេ ) ធ. បន្ធូរ ( „ បន្ទូរទេ)

ស. ពិសារ (មិនអាចជា ពិសាររទេ)

---

## ពាក្យដែលមានយុគលពិន្ទុ (ះ)

ពាក្យជាឯកតព្យាក្ខរដែលមានស្រៈអ ខាងចុង, កាលណា មិនមានសញ្ញាយុគលពិន្ទុទេ មិនត្រូវអានឲ្យចេញសូរជាអះទេ ៖

កម្ម, កាយ, រូប, សម្ពស្ស, ឧទ្ទិស, ចិត្ត ។ល។ មិនត្រូវអានថា កម្មៈ, កាយៈ, ។ល។ ទេ ។

- បើមានយុគលពិន្ទុ  ទើបត្រូវអានឲ្យមានសូរ អៈ ៖ កម្មៈ គណៈ ទស្សនៈ, វណ្ណៈ, សុខៈ, ពលៈ  ។ល។

បើពាក្យជាពីរព្យាង្គ ឬដែលតភ្ជាប់ជាបទពីរ (សមាស) ត្រូវអានភ្ជាប់គ្នា ឲ្យមានសូរស័ព្ទយុគលពិន្ទុជា អៈ ជាដរាប ៖

កាយកម្ម (កាយ+កម្ម) ត្រូវអានថា កាយៈកម្ម,

កម្មករ (កម្ម+ករ) „ កម្មៈ-ករ,

ធម្មតា „ ធម្មៈ-តា ។ល។

មិនត្រូវអានកំបុតសំឡេងថា កាយ-កម្ម, កម្ម-ករ, ធម្ម-តា ដូច្នេះទេ ។

## ពាក្យដែលមានស្រៈរស្សៈខាងចុង

ពាក្យដែលមានស្រៈរស្សៈ (អ.អិ អុ) នៅខាងចុង (ខេត្ត, ជាតិ, ហេតុ) គេច្រើនតែបំបាត់សំឡេងស្រៈរស្សៈចោល មិនអានឲ្យឮផងទេ ៖

អ = ខេត្ត, ខណ្ឌ, ឯកច្ឆន្ទ ។ល។

តិ = ជាតិ, បញ្ញត្តិ, វិបត្តិ, អនុម័តិ, ធម្មជាតិ ។ល។

តុ = ហេតុ, ធាតុ ។ល។

លើកលែងតែពាក្យខ្លះ ដែលនិយមអានជាទម្លាប់ជាប់តាមពីកំណើតផ្ទាល់ទាំងស្រុងមកហើយ, ពាក្យខ្លះទាំងនេះត្រូវអានទុកសម្លេងឲ្យគង់វង់នៅដដែល ៖

ញត្តិ (ញ៉ាត់-តិ), ប្រជាមតិ, បដិសន្ធិ, សន្និធិ, សិទ្ធិ, ឧត្តមគតិ, កម្មវត្ថុ, ហិរញ្ញវត្ថុ ។ល។

## ពាក្យដែលមានស្រៈរស្សៈនៅកណ្ដាល

ពាក្យដែលមានស្រៈរស្សៈនៅកណ្ដាល ត្រូវតែអានឲ្យមានសូរស័ព្ទរស្សៈ (សូរខ្លី) ជាដរាប ៖

កម្មករ (កម្-ករ), ធម្មតា, កិត្តិនាម, និតិក្រម, ផាតុកូត បតុកូមិ ។ល។

## ពាក្យដែលមានតួ "រ" ប្រកបជាមួយ

បើតួ "រ" នៅខាងចុងបំផុត "រ" ជាព្យញ្ជនៈឥត

សំឡេង មិនត្រូវអានឲ្យឮសូរជាអ្វីឡើយ៖

ត្រេកអរ, សាគរ, ឋានន្តរ, កម្មករ, ចារ, គោចរ, ទេពអប្សរ, ព្រះវេស្សន្តរ ។ល។

បើតួ «រ» ឋិតនៅត្រង់កណ្ដាលពាក្យ, «រ» មានសូរគង់វង់ជា "រ" ដដែល តែសូរខ្ញី-រហ័សភ្ជាប់ទៅនឹងបទខាងចុង៖

ពាក្យដែលធ្លាប់ប្រើ

បរទេស (ប-រ-ទេស), បរប័ក្ស (ប-រ-ប័ក្ស),

បរលោក (ប-រ-លោក), នរនាថ (ន-រ-នាថ) ។ល។

វៀរលែងតែពាក្យពីរម៉ាត់ខាងចុងនេះ, "រ" មានសូរជា «រ» វិញ៖

អន្តរជាតិ (អន្ត:-រ:ជាតិ)

វរជន (វ:-រ:-ជន់)

## ពាក្យដែលមានស្រៈ ា ប្រកប«រ» (ារ)

ពាក្យទាំងនេះ "រ" មានសំឡេងជា «ល» វិញ៖

កណ្ដុរ (កណ្ដុល), ខ្នុរ (ខ្នុល), ខុរ (ខុល), ខ្ពុរ (ខ្ពុល), ខ្យុរ (ខ្យុល), ធុរ (ធុល), បង្អុរ (បង្អុល), ផុសផុរ (ផុសផុល), ផ្កុរ (ផ្កុល), ផ្សុរ (ផ្សុល), ពពុរ (ពពុល), អសុរ (អៈសុល) ។

---

## ស្រៈ ិ អានជា ី

ពិដក (ពី-ដក់), បិតា (បី-ដា),

បិសាច (បី-សាច), វិថិ (វិ.ថី)

អវិចិ (អៈ-វិ-ចី) ។ល។

ចំណាំ.- វិថិ នឹង អវិចិ នេះ ជាសព្ទដើមនៃបាលីសុទ្ធសាធ តែខ្មែរយើងសរសេរក្លាយតាមគានថា វិថី, អវិចី ដូច្នេះទៅហើយ ។

## ស្រៈ ី អានជា ិ

ហីនហោច (ហិន-ហោច), អតីត (អៈ-ដិតឬ-ឌិត),

សន្និសីទ (-សិទ), ក្សីណក្ស័យ (ក្សិណក្ស័យ) ។ល។

កំណត់.- គេអាចសរសេរជា ហិនហោច, សន្និសិទ, ក្សិណក្ស័យតាមអានក៏បាន, តែចំពោះអតីត គេមិនដែលសរសេរជាអតិតទេ ។

ស្រៈ ិ នឹង ី ប្រកប « រ » អានជា « អើ »

សិរ្សមាន់ (សេរ-មាន់), ទឹកក្សីរ (ទឹក-ក្សេរ), ចីរកាល (ចេរ-កាល) ។ល។

---

## េ-យ្យ មានសូរជា -អ័យ

អធិបតេយ្យ (-ត័យ), ឧបមេយ្យ (-ម័យ), គណនេយ្យ (-ន័យ), ឧទេយ្យ (-ទ័យ), នាមាភិធេយ្យ (-ធ័យ), គេយ្យគាថា (គ័យ-), បាត្តេយ្យសាលា (-ត័យ-) ។ល។

## -េ- អានជា -ៃ-

ពាក្យក្លាយពីបាលី ឬ សំស្ក្រឹតដែលជាអឃោសៈ ខ្មែរ

យើងច្រើនអានបំប្លែង េ- ជា ែ- ៖

ចេតនា (ចែ-), ខេត្រ (.ខែត),

ខេត្ត (ខែត) ខេមរ (ខែម-រ៉) ។ល។

លើកលែងតែ ហេតុ, ហេមរដូវ ត្រូវអានថា ហែតុ, ហែមៈ រដូវ ។

– ដែលជាឃោសៈ ច្រើនអានថា -េ- ដដែល ៖

ប្រភេទ, វេជ្ជបណ្ឌិត, ផលនេត្រ, មេឃ, លេស, កិលេស, និវេសន៍, ប្រទេស ។ល។

វៀរលែងតែ ពេទ្យ ត្រូវអានថា ពេទ្យ ។

## ឃ. ឥតសំឡេង

អក្សរ «ហ» កាលបើប្រកបជាមួយនឹងជើង ្ន, ្ម, ្ល, ្វ ច្រើនតែបាត់សូររបស់ខ្លួន មានតែសំឡេងជើងព្យញ្ជនៈ ប៉ុណ្ណោះ ៖

ហ្ន (អ.ន.)

អ៊ីហ្ន! (–ន គានថា... ន សូរខ្ពស់ជាងនប្រក្រតី), អ្នកណាហ្ន!, អើហ្ន៎!, អើហ្នឹងហើយ! (–នឹង ), ហ្នាប៉ាក់ (ស.) (ណា.ប៉ាក់)= សំពត់ដែលគេប៉ាក់ពាសមុខទូកង, ខ្នុរហ្ន័ង, ហ្នាំង ឬ ណាំង (ស.) ។

ហ្ម (អ.ម៉)

ពេទ្យហ្ម(ស.)(–ម៉), ហ្មជ៏រ, ហ្មថាវ, ហ្មទូត (ស.) អ្នកប្រសប់ចាប់សរសៃ, ហ្មក្វាម (ស.) អ្នកស្មាក្តី, ហ្មង (ម៉ង) (ស.) សៅហ្មងចិត្ត, ហ្មត់(ស.) ហ្មត់ចត់ ឬ ម៉ត់ចត់(ស.), ហ្មត់-ហ្មង(ស.), អង្គុយហ្មប(ស.), ហ្មបហ្មយ, បុតហ្មក, នាហ្មឺន ឬ ម៉ឺន, មួយហ្មឺន ឬ ម៉ឺន, ហ្មូត ឬ ម៉ូត ។

ហ្ល (អ.ឡ)

ហ្លាក់ ឬ ឡាក់ហាន (ស.), ហ្លាក់ហ្លាំង ឬ ឡាក់ឡាំង (ស.), តាំងហ្លាយ ឬ តាំងឡាយ(ស.), ហ្លួង (ស.) ។

## ហ្វ (វ៉)

ហ្វង់ (វ៉ង់), ហ្វឹកហាត់, ហ្វឹកហ្វឺន, ហ្វុង, គាល់ហ្វៅ, ចៅហ្វាយ, ចានហ្វាន, ដហ្វា ។

## ហ្ស៊ (បារាំង J ឬ G)

ហ្ស៊េណេរ៉ាល់, អ័តហ្ស៊ុយដង់, រថយន្តហ្ស៊ីប ។ល។

## ស្ហ (បារាំង Ch)

ស្ហឺវ៉ាលីយេរ, ស្ហូហ្វ័រ ។ល។

---

## អើយ

១– បើព្យញ្ជនៈនៅខាងដើមជាប់នឹង «អើយ» មានសូរស្រួលស្តាប់ ដូចជា -ក, -ង, -ញ, -ន, -ម, -យ, -ស ជាដើម គេច្រើនអានភ្ជាប់ (liaison) សំឡេងព្យញ្ជនៈនេះទៅនឹង "អើយ" ៖

អ្នកអើយ! អានភ្ជាប់ថា អ្នក-កើយ!

នាងអើយ! អានភ្ជាប់ថា នាង-ង៉ើយ!

សំឡាញ់អើយ! „ សំឡាញ់-ញ៉ើយ!

ប្អូនអើយ! „ ប្អូន-ណើយ!

កម្មអើយ! „ កម្ម-ម៉ើយ!

យាយអើយ! „ យាយ-យ៉ើយ!

ម្ចាស់អើយ! „ ម្ចាស់-សើយ!

ព្រលឹងមាសអើយ! „ ព្រលឹង-មាស-សើយ!

២-បើពាក្យដែលនៅខាងដើម «អើយ» មានព្យញ្ជនៈតម្រួត (ព្រះអង្គ-អើយ) ឬពាក្យដែលឥតអក្សរប្រកប មានតែស្រៈទទេ (តា-អើយ), អើយ នឹងអានភ្ជាប់សំឡេងដូចបែបទី១ ពុំបានឡើយ ព្រោះបើភ្ជាប់ទៅនាំឲ្យមិនស្រួលស្ដាប់ ឬនឹងអានថា «អើយ» ទទេដូច្នេះ ក៏នៅតែមិនស្រួលស្ដាប់, ត្រូវអានថា "អ្ហើយ" ជាសំឡេងស្រាល!

ព្រះអង្គអើយ! ត្រូវអានថា ព្រះអង្គ-អ្ហើយ!

| | | |
|---|---|---|
| ភិក្ខុអើយ! | ត្រូវអានថា | ភិក្ខុ-អ្ហើយ! |
| ព្រះពុទ្ធអើយ! | „ | ព្រះពុទ្ធ-អ្ហើយ! |
| តាអើយ! | „ | តា-អ្ហើយ! |
| មាអើយ! | „ | មា-អ្ហើយ! |
| ពូអើយ! | „ | ពូ-អ្ហើយ! |
| ទេវតាអើយ! | „ | ទេវតា-អ្ហើយ! |

## ហោង៍ (អ្ហង៍)

ជាពាក្យបូរាណលោកច្រើនប្រើនៅពេលបញ្ចប់រឿង ដើម្បីឲ្យអ្នកស្ដាប់ឬអ្នកអានយល់ថា រឿងនោះចប់តែប៉ុណ្ណោះ ឥតមានតទៅទៀតទេ៖

– ចប់តែប៉ុណ្ណោះឯង៍ហោង៍ (អ្ហង៍) ។

– សូមឲ្យបានសម្រេចព្រះនិព្វានហោង៍ (អ្ហង៍) ។

# ពាក្យពិបាកក្នុងអនុពាក្យ

យើងបានចែកពាក្យពិបាកជា ៤ ពួក គឺពាក្យពិបាកដែលទាក់ទងដោយវណ្ណយុត្តិខ្លះ, ដោយស្រៈពេញតួ, ដោយស្រៈនិស្ស័យ, ដោយតួព្យញ្ជនៈ និងដោយសព្ទវេយ្យាករណ៍ ។

ក្នុងមួយពួកៗ យើងបានដកស្រង់ពាក្យជាឧទាហរណ៍យ៉ាងច្រើនស្ទើរតែគ្រប់គ្រាន់ សម្រាប់ជាគ្រឿងចំណាំដល់អ្នកសិក្សា ។ ចំពោះពាក្យពិបាកដែលទាក់ទងដោយស្រៈនិស្ស័យ (ក្រ និង គ្រ ប្រកបនឹងស្រៈ ួ - ឿ - ៀ) យើងបានដកយកតែខាងព្យញ្ជនៈណា ដែលមានចំនួនពាក្យតិចដូចជា ក្រ និង គ្រ, យើងលើកយកតែខាងព្យញ្ជនៈ គ្រ ជាឧទាហរណ៍ មាន ៧ ពាក្យ (គួច, គួរ, គ្រួចៗ, គ្រួសារ, គ្រឿង, គ្រឿន, គ្រៀស), ហើយខាងចុងយើងចុះ

សេចក្ដីសន្មតិថា «ក្រៅពីនេះ សុទ្ធតែជាអក្សរ ក ទាំងអស់» គប្បីអ្នកសិក្សា សង្កេតចំណាំតែខាងអក្សរ គ ៧ ពាក្យនេះប៉ុណ្ណោះ ក្រៅពីនេះ កាលបើមានពាក្យដែលប្រកបនឹងស្រៈ ួ-ឿ-ៀ មានសូរជា ក ឬ គ មិនដាច់ស្រេចនេះ ត្រូវតែអ្នកសិក្សាសរសេរខាងអក្សរ ក ទាំងអស់ចុះមិនខុសទេ ។ ឯពាក្យពិបាកដែលទាក់ទងដោយព្យញ្ជនៈ (ក្មេង ឬខ្មេង) ក៏មានលក្ខណៈដូចគ្នានឹងន័យនេះដែរ ។

---

## ពាក្យពិបាក
## ដែលទាក់ទងដោយវណ្ណយុត្តិខ្លះ

### រស្សសញ្ញាឬបន្តក់ ( ់ )

សញ្ញា ( ់ ) នេះ សម្រាប់ដាក់នៅលើព្យញ្ជនៈដែលជាស្រៈ "អ" (កប់) នឹងស្រៈ ា (កាប់) នៅខាងដើម ដើម្បីបំប្លែងសំឡេងឲ្យខ្លីកំបុត៖

៩. កត់, អំណត់, ចប់, កាល់, ចាប់, អាប់ ។ល។

ចំណាំ.– ១– ចំពោះស្រៈ ា ប្រកប «ន៍» ខាន់ចុន មិនត្រូវដាក់បន្តក់ ( ់ ) នេះទេ ត្រូវប្រើនិគ្គហិត ( ំ ) នេះនៅពីលើស្រៈ ា ជំនួសវិញ៖

៩. កាំង, ខាំង, គាំង, ឃាំង, ចាំង, មាំង ។ល។

មិនដាក់បន្តក់នៅលើ «ង៍» ជា «កាង់, ខាង់, គាង់, ឃាង់, ចាង់, មាង់» ដូច្នេះទេ ។

២– ចំពោះស្រៈ ា ប្រកប «ច» ខាន់ចុន អាចដាក់បន្តក់បានទាំងអស់ ។ វៀរលែងតែពាក្យទាំងប៉ុន្មានខាងក្រោមនេះ ដែលមានសំឡេងដូចស្រៈ ា ប្រកប "ច" ដែរ តែបែរជាត្រូវដាក់ស្រៈ េច ជំនួសវិញ៖

សេចក្ដី, សេចក្ដាំ, ស្រេច, សម្រេច, សម្ដេច, ស្ដេច ម្ដេចា, ផ្ដេច ។ (អានថា-សាច់ក្ដី, ស្រាច់, ស្ដាច់, ផ្ដាច់)

៣- សេស្រញ្ញា ឬ បន្តក់នេះ ប្រើបានចំពោះតែពាក្យខ្មែរសុទ្ធប៉ុណ្ណោះ ឯពាក្យក្លាយមកពីបាលីឬសំស្រ្កឹតដែលមានព្ឋស្បវ័ទ្ធ-កំបុតដូចជាសេស្រញ្ញាដែរនោះ មិនចាំបាច់ប្រើបន្តក់នេះទេ ។

## ពាក្យឥតបន្តក់ដែលធ្លាប់ប្រើ

| | |
|---|---|
| កុសល (កុសល់) | កុហក (កុហក់) |
| អាគម (អាគម់) | អនាគត (អៈណា-គត់) |
| ជន (ជន់) | ផល (ផល់) |
| កត (កត់) | មណ្ឌល (មន់-ឌល់) |
| ធន (ធន់) | តាបស (តា-បស់) |
| នាយក (នាយក់) | ជាតក (ជាដក់) |
| អាជីវក (អាជីវក់) | នរក (ន-រក់) |
| លាមក (លាមក់) | ភ្លក្ស (ភ្លក់) |

សុគត (សុគត់)     ទុគិត (ទុគិត់)

ទុពិល (ទុពិល់)     ទុយិស (ទុយិស់)

## ត្រីស័ព្ទ ( ៊ )

វណ្ណយុត្តិនេះ សម្រាប់ដាក់តែនៅលើព្យញ្ជនៈ ៤ តួគឺ ប ស ហ អ ដើម្បីបំប្លែងសំឡេងតូច (អ) ទៅជាសំឡេងធំ (អ៊) ប៊ ស៊ ហ៊ អ៊ ៖

ឧ. ប៊ុន, ស៊ង, ហ៊ាន, អ៊ុន ។

— លោកប៊ិនទិញកៅស៊ូពីក្រុមហ៊ុនស៊ុន ។

ចំណាំ. ១- ចំពោះព្យញ្ជនៈ ប៊ ខ្មែរយើងមានប្រើតែ សាប៊ូ មួយប៉ុណ្ណោះ ក្រៅពីនេះគេច្រើនប្រើក្នុងពាក្យឈ្មោះរបស់មនុស្ស ដូចជាឈ្មោះ ប៊ន, ប៊ុត, ប៊ុន ជាដើម។

២.- ស៊ ហ៊ កាលណាមានស្រៈ ( ិ ី ឹ ឺ )

នៅខាងលើត្រូវផ្លាស់ (៊) នេះ ទៅជាក្បៀសខាងក្រោមវិញ (ុ)៖

១. ស៊ី, ម៉ាស៊ីន, កូសាំងស៊ីន, លេងហ៊ី, ហ៊ីហា ។ល។

៣- ស៊ិ ហ៊ិ កាលណាមានសំឡេង (ុំ) នៅជាមួយ មិនត្រូវដាក់ ំ នៅពីលើ ៊ (ុំ), ត្រូវផ្លាស់ ំ ជា «ម» វិញ៖

១. ស៊ិមគ្រលុំ, ស៊ិមទ្រុម, ស៊ិមមាន់, ហ៊ិមព័ទ្ធ, ផាហ៊ិម, ល្ហោនហ៊ិមកេង, ហ៊ិមហ ។ល។

មិនត្រូវសរសេរ ស៊ុំ, ហ៊ុំដូច្នេះទេ ។

៤- ស៊ បើមានសម្លេង( ាំ )នៅជាមួយត្រូវផ្លាស់ (៊) នេះទៅជាក្បៀសក្រោមវិញ (ុ)៖

១- ស៊ាំប៉ិត្ត, ស៊ាំគំទិត, ស៊ាំកម្លាំង, ស៊ាំស៊ិន ។ល។

មិនត្រូវសរសេរ ស៊ាំ ដូច្នេះទេ ។

៥- អ៊ី បើមានស្រៈ( ិ ី ឹ ឺ )នៅពីលើមិនត្រូវផ្លាស់

(៉) ទៅជាក្បៀសក្រោម (ុ) ដូចជា ស៊ី ហ៊ី ទេ ត្រូវទុកឲ្យ នៅដដែល៖

១– អ៊ះអ៊ុះ, អ៊កអ៊ាក់, អ៊ៃ, អ៊កអ៊ាក, អ៊ឺប, អ៊ុប, អ៊ុះ, អ៊េះ, អ៊ែត, អ៊ោ: អ៊កអ៊ឹក ឬ អ៊កអ៊ឹក, អ៊ឹ, អ៊ឹម ឬ អ៊ឹមអ៊ោះ, អ៊ិះ, អ៊ិះអ៊ិះ, អ៊ុះអ៊ះ, អ៊ី, អ៊ីត, ក្រូចអ៊ីត, អ៊ីៈ ៗ

## មូសិកទន្ត ឬ ធ្មេញកណ្ដុរ (៉)

សញ្ញា (៉) នេះ សម្រាប់ដាក់នៅលើព្យញ្ជនៈ ៩ តួគឺ ង ញ ន ប ម យ រ ល វ ដើម្បីបំប្លែងសំឡេងឲ្យទៅជា ង៉ ញ៉ ន៉ ប៉ ម៉ យ៉ រ៉ ល៉ វ៉ ៖

១. បុណ្យង៉ាន, ញ៉ាម, ម៉ោង, វៀនវ៉ាវ, ព៉ន់ស៊ុយ ៗល ៗ

ចំណាំ.–១– បើកាលណាមានស្រៈ( ិ ី ឹ ឺ ើ ំ)

នៅពីលើ ត្រូវផ្លាស់ (") ទៅជាក្បៀសក្រោម (,) វិញ៖

១. ប៊ុ, ម៊ុងម៉ាត់, ញ៉ុំា ។ល។

២– បើកាលណា មានពាក្យពីរព្យាង្គ ហើយព្យាង្គខាងមុខមានសំឡេងស្របទៅតាមព្យាង្គខាងដើម ក៏មិនត្រូវប្រើ (") ដែរ៖

១ កន្ទល់, បញ្ញា, ប្រមាថ, ស្រវឹង, ចម្លែក ។ល។ មិនត្រូវសរសេរ: កន្ទ៉ល់, បញ្ញ៉ា, ប្រម៉ាថ, ស្រវ៊ឹង, ចម្ល៉ែក ដូច្នេះទេ ។

## សំយោគសញ្ញា ( ័ )

សញ្ញា ( ័ ) នេះ សម្រាប់ដាក់នៅលើព្យញ្ជនៈ ជាស្រៈ (អ) ទី២ (កប់ពីខាងស្តាំដៃមកឆ្វេង) ដើម្បីបំប្លែងសំឡេងដើមឲ្យទៅជាស្រៈ ៃ - ឬ - ា ប្រកបនឹងព្យញ្ជនៈ

ខាងចុង ៗ គេប្រើចំពោះពាក្យដែលក្លាយពីបាលី ឬ សំស្ក្រឹតមកៈ

១. ក្ស័យ, ជលស័យ, ពិសម័យ, ជ័យ, វិន័យ, ន័យ, ជលន័យន៍, និនក្ស័យ, ទ័លក្រ, ភ័យ, វិស័យ, និស្ស័យ, ទិព្វ័ន, វិនិច្ឆ័យ, ទេពវិនិច្ឆ័យ, នភាល័យ, អាល័យ, សម័យ, អនាម័យ, និរភ័យ, នព្វ័តន៍, ឧត្ដលវ័យ, ពនាល័យ, រហ័ស, អាស្រ័យ, វេស្ម័ន, វេស្ស-វ័ណ្ណ, បរិស័ទ, បរាសម្ព័ទ, ប្រល័យ, ប្រាស្រ័យ, ពិជ័យសង្គ្រាម, អាគ្ម័ន, វិទ្យាល័យ, បណ្ណាល័យ, ត្រ័យត្រឹង្ស, ព្រះទ័យ, មនោម័យ, ក្សីណក្ស័យ, ប្រល័យ-កល្ប, អយស្ម័យយាន, ពិនិច្ច័យ, អាយ័ត, បច្ច័យ, នំប័ក្កប័ន, ប្រប័ណ្ឌ, ប្រយ័ត្ន, ភ័ព្វ, ប្រវ័ញ្ច, និលរ័ត្ន, នារីរ័ត្ន, ភ័ក្ត្រ, ពិភ័ក្តិ, ល័ក្ខ័ណ្ឌ, ម្រ័ក្សណ៍, លាយល័ក្ត-អក្សរ, ស័ត្ត, ស័ព្វ, ស័ក្តិសិទ្ធិ, ស្រអ័ព្វ, ស្ម័គ្រ ៗ

គ័តិ, ទក្ខិណាព័ត, ព័ណ៌, ព័ទ្ធ, ព័ន្ធព័ទ្ធ, ពិទ័គ្ធ, យ័ន្តឬយ័ន្ត្រ, ល័ទ្ធ, ពិព័រណ៌ ។

ចំណាំ.– ១–សំយោគសញ្ញា ( ័ ) នេះ គេប្រើក្នុងពាក្យខ្មែរសុទ្ធក៏មានខ្លះ៖

១. ខ្ញ័រ, ជ័រ, ញ័រ, ទទ័រ, ទ្បទ័រ, ទំព័រ, ខំប័ុង, ស្បូរប៉ុង, ក្ឈ័រ, ផ្លែសង្ស័រ, ដើមសំព័រ, ស្ពាន់ជ័រ ។

២– ក្នុងពាក្យបារាំងដែលសរសេរជាអក្សរខ្មែរក៏មានខ្លះ៖

១. ដុកទ័រ, ឌីរ៉ិកទ័រ, អ័ងស្ប៉ិកទ័រ, កុងត្រូល័រ, ស្បូហ្វ័រ ។

## របាទ(៌)

សញ្ញា ( ៌ )នេះ សម្រាប់ប្រើចំពោះតែពាក្យ ដែល

ក្លាយមកពីសំស្រ្កឹតប៉ុណ្ណោះ ដើម្បីបំប្លែងសំនៀងឲ្យព្ទស្សរ ញ៉័រ៖

## ពាក្យដែលធ្លាប់ប្រើ

១. គភ៌, ទុគ៌ត, ទុព៌ល, ទុគ៌ម, ទុយ៌ស, ធម៌, បព៌ត, ពណ៌, អាថ៌, ពត៌មាន (ព័រ-ដមាន), ទ៌ទុ៌ក្ខ, ទ៌ភ៌យ ។ (ពាក្យទាំងនេះក្លាយមកពីបាលីថា គព្ភ, ទុគ្គត, ទុព្វល, ទុយ្យស, ធម្ម, បព្វត, វណ្ណ, អត្ថ, វត្តមាន, ទ៌ទុក្ខ, ទ៌ព្ភយ ។

ចំណាំ.– ១ កាលណាមានស្រៈ ៌ នៅជាមួយ, ដើម្បីជៀសវាងកុំឲ្យមានការទើសទាស់ច្រើន, ត្រូវដាក់អក្សរ «រ» ពេញតួពីលើព្យញ្ជនៈខាងចុងតែម្ដង៖

១. ពមកើ្តរ៍, ទុក្ករ, តិរ្ឆយ, អន្យតិរ្ឆយ ។

២.– ពាក្យខាងក្រោមនេះ ក៏ខ្មែរយើងនិយមសរសេរអក្សរ «រ» ពេញតួដែរ ៖

៤. អារ្យធម៌, អស្ចារ្យ, អាចារ្យ, អនាចារ្យ ។

៣- ពាក្យខាងក្រោមនេះ អាចប្រើបានពីរបែប ៖

ទុគ៌ម, ទុព៌ល, ទុយ៌ស, ទុគ៌ត, បព៌ត, និទ៌ុក្ខ, និភ៌យ; បើសរសេរ "រ" ពេញតួ: "ទុរគម, ទុរពល, ទុរគត, បរពត, និរទុក្ខ, និរភ័យ" ដូច្នេះក៏បាន ។

## ទណ្ឌឃាត (៍)

សញ្ញា (៍) នេះ សម្រាប់ដាក់នៅលើព្យញ្ជនៈខាងចុង នៃពាក្យ ដែលក្លាយពីបាលីនិងសំស្រ្កឹត ដើម្បីសម្គាល់ សំឡេងតួអក្សរនោះកុំឲ្យឮសូរ ៖

ពាក្យដែលធ្លាប់ប្រើ

ប្រយោជន៍, អាពាហ៍ពិពាហ៍, ព្រះមហាក្សត្រិយ៍, ព្រះ

ភជទិវេសន៍, វេហាស៍, យោជន៍, រុងរេចន៍, អកិរូហ៍, វេយ្យា-ករណ៍, សហករណ៍, ព្រឹត្តិការណ៍, អ្នកចោទក៍, អ្នកពេជ្ឈ-ឃាតក៍, អ្នកឧបត្ថម្ភក៍, ការប្រវ័ញ្ចន៍, ការពិសោធន៍, ការអនុ-វត្តន៍, ការបរិវត្តន៍, ការបដិវត្តន៍, ស្រមណ៍, ព្យាករណ៍, ដំណើរនិវត្តន៍, ភេទ៍, ថ្ងៃសៅរ៍, ខែស្រាពណ៍, សតវត្សរ៍, ពិព័រណ៍, ភ្នំព្រះសុមេរុ៍ (សុ-ម៉ែ), ក្រាបប្រណិប័តន៍, និវេសន៍, ហេតុការណ៍ ។

## លេខអដ្ឋ ( ៏ )

សញ្ញា ( ៏ ) នេះ សម្រាប់ដាក់នៅលើព្យញ្ជនៈបួនតួគឺ ក, ដ, ហ, ន ដែលជាពាក្យខ្មែរសុទ្ធ ដើម្បីបំប្លែងសំឡេងឲ្យឮស្រួល៖

## ពាក្យដែលធ្លាប់ប្រើ

ក៏ = ក៏ដោយ, លោកក៏ដោយ, ខ្ញុំក៏ដែរ, ក៏បាន ។

ដ៏ = ដ៏ប្រសើរ, ដ៏ឧត្តម, ដ៏ខ្ពង់ខ្ពស់, ដ៏ហើយ (បានន័យថាសង់, ធ្វើ) ។ ឮដ៏: (បានន័យថា ឯ)

ហ៏ = ហ៏យកក់ទៅ ។

ន៏ = នុះន៏ ។

កំណត់ :– ១ ក ជាកិរិយាស័ព្ទ និងនាមស័ព្ទមិនត្រូវដាក់ ( ៏ ) ទេ កសាង, កមនុស្ស ។

២– ដទៃ, ដពង, ដដែល, មិនត្រូវដាក់ ( ៏ ) ទេ ។

## យុគលពិន្ទុ ( : )

សញ្ញា (:) នេះ សម្រាប់ចុចនៅមុខពាក្យក្លាយមកពីបាលីនិងសំស្ក្រឹត ដើម្បីសំគាល់ឲ្យដឹងថា ព្យញ្ជនៈដែលមាន

ចុច (:) នេះត្រូវអានឲ្យមានសំឡេងជា «អាក់» (អ:)៖

## ពាក្យដែលធ្លាប់ប្រើ

គណៈ, ទស្សនៈ, ធុរៈ, វណ្ណៈ, សុខៈ, ពលៈ, ភារៈ, ថាវរៈ, ឃោសៈ, អាជីវៈ, បការៈ, ទោសៈ, បដិសណ្ឋារៈ, សម្ភារៈ, វីរិយៈ, បស្សាវៈ, រស្សៈ, ទីឃៈ, អក្ខរៈ, ព្យញ្ជនៈ, ភាវៈ, ភេសជ្ជៈ, មរណៈ, លក្ខណៈ, លាភៈ, លោភៈ, ទោសៈ, មោហៈ, ភាជនៈ, សក្ការៈ, សមណៈ, សម្បជញ្ញៈ, ខេមរៈ, ស្រៈ, សារៈ, សភាវៈ, សេនាសនៈ, អមតៈ, អាយតនៈ, ឧបការៈ, មោឃៈ ។

បំណាំ.– ១ ពាក្យណាជាសមាសនាម (ដែលមានបទពីរតភ្ជាប់គ្នា: ខេមរ + ភាសា = ខេមរភាសា) ត្រូវអានឲ្យមានសំឡេងដូចជាមាន (:) ដែរ តែមិនត្រូវ ចុច (:) នេះជាដាច់ខាត៖

យុវជន, យុវនារី, ឧបការគុណ, វិស្សមកាល,

មរណភាព, ខេមរជាតិ, បដិសណ្ឋារកិច្ច, ព្រះរាជបុត្រ, សក្ការបូជា, អាជីវកម្ម ៗ

(មិនត្រូវចុច : យុវ:ជន ដូច្នេះទេ)

២– ចំពោះពាក្យ "គណៈ" ទោះបីភ្ជាប់ដោយបទពីរបីខាងចុង ក៏នៅតែប្រើ (:) នេះជាដរាប ព្រោះបើមិនចុច អ្នកអានអាចប្រឡំអានថា គណ (គន់)៖

## ពាក្យដែលធ្លាប់ប្រើ

គណៈសង្ឃ, គណៈបក្ស, គណៈកម្មការវប្បធម៌, គណៈរដ្ឋមន្ត្រី, គណៈបេសកកម្ម, គណៈប្រតិភូ ៗ

៣– យុគលពិន្ទុនេះ មានប្រើក្នុងពាក្យខ្លះខ្លះដែរ តែត្រូវអានឲ្យមានសូរខ្លីកញ្ចក់៖

ទេហ:, ហឹ:, ហោ:, ហៃ: ៗ

៤– កុំចុចសញ្ញា (:) នេះឲ្យមានរង្វង់មូលដូចរះមុខ (ះ) ៗ

# ការហាត់សាឡើងវិញ

*ចូរកែពាក្យខាងក្រោមនេះ តាមពាក្យដែលបានសិក្សា រួចមកហើយ ៖*

| ពាក្យខុស | ពាក្យត្រូវ |
|---|---|
| ផ្លូវទៅកាន់ត្រពាំង មានដើមក្រសាំងដុះឃាំងពាំងពីមុខ ។ | |
| មហាវេស្សន្តរផាផក់ និយាយថាពាផ្លូផក់ផាមនុស្សទុគិត, ជំណើរអ៊ុកអ៊ាក, សាបសូន្យបាតមង់អាត់ក៏ដើរភ្ជូតកុហក់សុំទានគេធីគ្រប់ភាប់ធណ្ដាល់ ពារលើព្រៃស៊ុំប្រុំម្លួយ ត្រូវផ្អែបៅបេតបុត្រហ៊ុព័ទ្ធផិត ស្មើរនឹងក្បៀរផិន ។ | |
| សេចក្ដីប្រម៉ាត ធ្វើឲ្យមនុស្សប្រាសបាកស្មារតីម៉ឹងម្ុាត់ ។ | |
| គណកម្មៈការអត្ថៈរៈជាតិបានប្រ-តិបត្តិការ៍ណេ បំបាត់នូវស្ថានៈការ៍ណភអាប់អួរក្នុងប្រទេស ។ | |
| ខ្ញុំក៏ដោយ អ្នកក៏ដែរ យើងមិនអាចដឹងចិត្តអ្នកដ៏ទៃឲ្យបានជាក់ជាធ័-ភាប ។ | |

# ពាក្យពិបាក

## ដែលទាក់ទង់ដោយស្រៈពេញតួខ្លះ

## ឥ, ឦ, ឧ, ឩ, ឫ, ឬ, ឭ, ឮ, ឯ, ឰ, ឱ, ឳ

### ឥ

មានសូរបែបគឺ អិ, អី, អឹ

ពាក្យដែលធ្លាប់ប្រើ

ឥ អានថា អ៊ិ

ឥតមាន, ឥដ្ឋក្រាល, ព្រះឥន្ទ្រ, ឥន្ទធនូ (ឥន-ទៈ-ធនូ), ឥន្ទជិត, ឥណ្ឌៀ, ឥណ្ឌូចិន, ឥន្ទនិល, ឥន្ទ្រវង្ស, ឥន្ទ្រិយ សត្វឥន្ទ្រី, ឥរិយាបថ (អិ-រ៉ិយ៉ា-បត់) ឥន្ទ្រាធិរាជ ឬ ឥន្ទ្រាធីរ ។

ឦ អានថា អ៊ី

ឥស្សរ, ឥស្សរេខៈ ។

ឥ អានថា អិ

ឥសី, ឥសូរ, ឥស្សរៈ, ឥធលោក, ឥណទាន, ឥទ្ធា-នុភាព, ឥដ្ឋា, ឥដ្ឋារម្មណ៍, ឥត្ថាគារ ៗ

(ពាក្យបាលីទាំងអស់)

ឦ អានថា អី

ទិសឦសាន, ឦសូរៈ, ឦសធរ, ឦស ៗ

(ពាក្យនេះឲ្យអានថាអីវិញៈ ឦសូរ)

ឧ មានសូរពីរយ៉ាងគឺ អុ, អ៊ុ

ឧ អានថា អុ

ពាក្យដែលធ្លាប់ប្រើ

ឧកញ៉ា, ឧសដុត, ឧកប្ដ·អុក, ឧកហ្វូង ៗ

ឧ អានថា អ៊ុ (សុទ្ធតែជាពាក្យបាលី-សំស្ក្រឹត៖

ឧកាសៈ, ឧក្រិដ្ឋ, ឧក្កោសនស័ព្ទ, ឧច្ចារៈ, ឧទរ, ឧប-យុវរាជ, វត្តឧណ្ណាលោម, ឧត្តុង្គ, ឧដុង្គឧត្តម, ឧទកៈ, ឧទាហរណ៍, ឧភតោសុជាត, គោឧសភ, ខែឧសភា, ឧទុម្ពរ, ឧទ្ទិស, ឧទ្យាន ឬ ឩទ្យាន, ឧបករណ៍, ឧបការី, ឧបការៈ, ឧបជ្ឈាយ៍, ឧបត្ថម្ភ, ឧបទ្រព, ឧបនិស្ស័យ, ឧបមា, ឧបមេយ្យ, ឧរ, ឧស្សាហកម្ម, ឧឡារិក, ឧម្មត្តកពេត (ពេតឆ្កួត), ឧទ្ធរណ៍ (ឧទ្ធរ), ឧទ្ធាគបក្រ ។

## ឪ អានថា អ៊ូវ

ឪពុក, ឪដំ, ឪជ្រឹង, ឪណុល, ឪទិន, ឪម៉ាល់, ឪឡ្យ, ឪឡឹក, ឪឡុង, ឪឡោក ។

## ឫ អានថា រឹ

## ពាក្យខ្មែរ

ឫក, ឫកពា (មារយាទ), ឫស, ឫសដី, ឫសដូង, ឫស្សី ។

## ពាក្យក្លាយពីសំស្រ្កឹត

ឫក្សពារ (ថ្ងៃ១), ឫទ្ធានុភាព, ឫសី (បា:ឥសី), ឫទ្ធិ, ឫសីថ្ងៃសារ, ឫស្យា ។

## ឬ អានថា រឺ

តែឬទេ ? មាសឬប្រាក់ ? ទៅឬមិនទៅ ? ឬនឹងថាជននេះជាចោរក៏ពុំបាន ។

## ឭ អានថា លឹ

រឭក, រំឭក (គេសរសេររលឹក, រំលឹក) ក៏ត្រូវ ។

## ឮ អានថា លឺ

ឮឬមិនឮ ? ខ្ញុំឮហើយ ។

## ឯ

ចំពោះពាក្យក្លាយមកពីបាលី ឬសំស្រ្កឹត អានថា អែ ឬ អេ, តែគេច្រើនអានថា អែ ជាង ដើម្បីកុំឲ្យពាក្យក្លាយទាំង

នោះនៅសូរតាមភាសាដើមសុទ្ធពេក៖

## ពាក្យដែលធ្លាប់ប្រើ

ឯកោ, ឯកា, ឯកជន, ឯកឧត្តម, ឯកច្ឆន្ទ, ឯកទេស, ឯកអគ្គរាជទូត, ឯករ័ណ, ឯកស័ក, ឯកអង្គ, ឯកំ, ឯកប្យ-ហារ, ឯកឯង, ឯកសណ្ឋាន, តួឯក, ល្អឯក, ឯកភាព, ឯកបុត្ត, ឯកបទ, ឯកបថ, ឯកពជ្យ, ឯកភាគ ៗ

## ពាក្យខ្មែរសុទ្ធ

ឯ, ឯណា, ឯណោះ, ឯណោះ, ឯង, ឯក ឬផែក ផ្ទង ៗ

## ព្ធ អាចថា អៃ

ចំពោះពាក្យក្លាយពីសំស្ក្រឹត

ព្ធករ័ណ, ព្ធសូរ ៗ

## ពាក្យខ្មែរសុទ្ធ

### ឮដ៏

មានន័យថា ក្នុង ឬ នៅពេលនោះ : ឮដ៏កាលនោះ

-,,- ឯ, នៅ: ឮដ៏អាកាស, វេហាស៍ ។

## ឱ អានថា [អោ]

### ពាក្យបាលី ឬ សំស្ក្រឹត

ឱកាស, ពជឱរស, ឱង្ការ, ឱសថ, ឱជារស, ឱដ្ឋជៈ, ឱភាស, ឱវាទ, ឱស្ឋ, ឱក ។

### ពាក្យខ្មែរសុទ្ធ

ឱ អនិច្ចា!, ឱះឱ! (អុះ-អោ), ឱន, ឱប, ឱក, ឱយ (និយមសរសេរ: ឲ្យវិញ), ឱហាត ។

ត្រី គានជា អ្រៅ

មានតែមួយមាត់ គឺ ឈូក ឬ ឈូក (រុក្ខជាតិដែលរស់នៅក្នុងទឹកដូចជាត្រកួន, កញ្ឆែត ជាដើម) ។

# ពាក្យពិបាក

## ដែលដាក់ដោយស្រៈទិសស្ស័យ

## ស្រៈ ិ ឬស្រៈ ឹ ?

បើតាមសំឡេងអក្ខរវិធី ស្រៈទាំងពីរនេះមានសូរផ្សេងពីគ្នាដោយឡែក តែបើតាមកាសាទិយម ខ្មែរយើងច្រើនគានឲ្យមានសូរដូច ៗ គ្នាទៅវិញ ជាហេតុនាំឲ្យអ្នកស្ដាប់ច្រឡំបាន ៗ ដើម្បីជៀសវាងការស្ទាក់ស្ទើរចិត្ត ក្នុងការសរសេរស្រៈ ិ ឬស្រៈ ឹ នេះ គេអាចញែកវែកឃើញថា៖

### ចំពោះពាក្យខ្មែរសុទ្ធ

១ - កាលណាមាន ក, ង, ម ប្រកបខាងចុង គេច្រើនតែដាក់ស្រៈ ឹ ជានិច្ច៖

ក– ទឹក, ផឹក, នឹក, ដឹក, ត្រឹក, រលឹក, ក្តឹក, ញឹក ។ល។

ង– ទទឹង, នឹង, ដឹង, ប្រឹង, ត្រលឹង, ស្ទឹង, រឹង ។ល។

ម– ខឹម, នឹម, ញញឹម, រលឹម, ផ្ងឹម, ស៊ឹម ។ល។

២– ព្យញ្ជនៈ ត ប្រកបចុង មានតែបីពាក្យប៉ុណ្ណោះ ដែលប្រកបនឹងស្រៈ ឹ ផាន៖

១. ដើមព្រលឹត ឬ ព្រលិត, រំរឹត, ងងឹត ។

ក្រៅពីពាក្យបីម៉ាត់នេះ ត្រូវសរសេរជាស្រៈ ិ ទាំងអស់ ។

៣– កាលណា មានព្យញ្ជនៈ ប, ន, ម, ល នៅខាងចុង គេត្រូវសរសេរប្រកបស្រៈ ិ ទាំងអស់ ។

ចំពោះពាក្យក្លាយពីបាលី

កាលណា មានព្យញ្ជនៈប្រកបខាងចុងដូចជា ក, ត, ខ, ឆ, ន, ស ជាដើម ត្រូវសរសេរស្រៈ ិ ជាដរាប៖

១. ព្រះធាតុធម្មិក, អនាមិក, ហេរញ្ញិក, បុគ្គលិក, ឃោសនិក, ធនិក, ចេតសិក, ខ្សារិក ។ល។ ចិត្ត, មិត្ត, វិបរិត, បណ្ឌិត, ចិត្តប័ណ្ណ ។ល។ គោរិខ ។ល។ ខស.

ពិធ, ពិពិភ័ណ្ឌ ។ល។ ទិស, ទ្វិស, អាមិស ។ល។

### បំពោះពាក្យក្លាយពីសំស្ក្រឹត

កាលណាមាន ក្យ, ត្យ, ត្ត, ត, ប្រកបខាងចុងច្រើន តែសរសេរជាស្រៈ -ឹ ជានិច្ច៖

១. ព្រឹក្សា, ទ្រឹក្យ, ប្រឹក្សា ។ល។ អព្យាក្រឹត្យ, សុក្រឹត្យ ។ល។ ប្រព្រឹត្ត ។ល។ ម្រឹគ ។ល។

---

### កួរ ឬ គួរ ?
### ចឿ ឬ ជឿ?
### កៀ ឬ គៀ ?

ខ្ញុំសង្កេតឃើញថា ក នឹង គ, ខ នឹង ឃ, ច នឹង ជ, ឆ នឹង ឈ, ដ នឹង ឌ, ឋ នឹង ឍ, ត នឹង ទ, ថ នឹង ធ, ប៉ នឹង ព, ផ នឹង ភ កាលណាប្រកបជាមួយនឹងស្រៈ ួ -ឿ- ៀ តែងមានសំឡេងដូចៗគ្នា ជាហេតុនាំឲ្យអ្នកសរសេរភ័ន្ត

ប្រចាំ ។ ដើម្បីដោះស្រាយពាក្យជាគូ ៗ ដែលមានសូរដូចគ្នានេះ គប្បីអ្នកសិក្សាសង្កេតចំណាំតាមវិធីដូចតទៅ៖

ក ទីន គ ផ្សំជាមួយស្រៈ ួ ឿ ៀ

គ មានតែ៧ពាក្យប៉ុណ្ណោះគឺ:

គួច, គួរ (គួរសម, គួរស្រូវ), គ្រួចៗ, គ្រួសារ, គ្រឿង, គ្រឿន, គ្រៀស (សំពប់រុំខ្លោច) ។

ក្រៅពីនេះសុទ្ធតែជាអក្សរ ក ទាំងអស់ ។

---

ខ ទីន ឃ ផ្សំជាមួយស្រៈ ួ-ឿ-ៀ

ឃ មានតែ៣ពាក្យប៉ុណ្ណោះគឺ:

ឃួច (ទន់ឃួច), ឃៀនឃ្លាត, ក្របីឃៀច ។

ក្រៅពីនេះ សុទ្ធតែជាអក្សរ ខ ទាំងអស់ ។

---

ប ទឹង ប ផ្សំជាមួយស្រៈ ួ-ឿ-ៀ

ប មានតែ១០ពាក្យប៉ុណ្ណោះគឺ :

ពាក្យបួន, បួនឬជួនណា, បួបឬជួប, សត្វបៀមឬបៀមខ្លួន, បៀរ, ប្រៀត, ប្រៀង, ប្រៀប, ប្រៀប, ហោះប្រៀវប្រែ ។

ក្រៅពីនេះ សុទ្ធតែជាអក្សរ ប ទាំងអស់ ។

---

ឈ ទឹង ឈ ផ្សំជាមួយស្រៈ ួ ឿ-ៀ

ឈ មានតែ៩ពាក្យប៉ុណ្ណោះគឺ :

ឈួលឬឆ្ងួល, ប្រឈួន, ឈៀម, ឈ្នួតក្បាល, ឈ្នួល, ឈ្នួញ, ឈ្នួយ (ហៃហាន), ឈៀស, ឈ្នៀង ឬឆ្នៀង (របៀងផ្ទះ) ។

ក្រៅពីនេះសុទ្ធតែជាអក្សរ ឈ ទាំងអស់ ។

---

ដ ទឹង ឌ ផ្សំជាមួយស្រៈ ួ - ឿ - ៀ

មានតែអក្សរ ដ ប៉ុណ្ណោះ, ខាង ឌ មិនមានទេ ។

---

ឋ ទឹង ឍ មិនមានស្រៈ ួ - ឿ - ៀ ផ្សំជាមួយទេ ។

---

ណ ទឹង ន ផ្សំជាមួយស្រៈ ួ - ឿ - ៀ

មានតែអក្សរ ន ប៉ុណ្ណោះ, ខាង ណ មិនមានទេ ។

---

ត ទឹង ទ ផ្សំជាមួយស្រៈ ួ - ឿ - ៀ

ទ មានតែ ១៣ ពាក្យប៉ុណ្ណោះគឺ:

ទួល, ទៀង, ទៀត, ទៀន, ដើមទៀបឬគៀប, ទួងឬទូង, ទួនឬគួន (ពាក្យផ្កាថាលោក,អ្នក), ទួទៅឬទូទៅ, ទួទ័រឬទូទ័រ, ទួញយំ, ទួម (ដែលរួមបូល), ទ្រៀស (បន្ទោះលប), ឈើទ្រៀក ។

ក្រៅពីនេះសុទ្ធតែជាអក្សរ ឥ ទាំងអស់ ។

---

ប ទឹង ភ ផ្សំជាមួយស្រៈ ួ-ឿ-ៀ

ភ មានតែមួយពាក្យគឺ :

ប្រហភួង ឬ ភុង ។

ក្រៅពីនេះសុទ្ធតែសរសេរជាអក្សរ ប ទាំងអស់ ។

---

ប៉ ទឹង ព ផ្សំជាមួយស្រៈ ួ-ឿ-ៀ

ព មានតែ ២០ ពាក្យប៉ុណ្ណោះគឺ:

ពួក, ពួច, ពួត, ពួន, ពួយ, ខ្សែពួរ, សត្វពៀក, ពៀច, ទូកពៀច, ចងពៀរ, ព្យួរគារ, ហើមសាច់ព្រួក, ត្រីព្រួច, ព្រួញ, ព្រួត, ព្រួយ, ត្រីព្រួល, ព្រួសទឹក, ព្រៀនលាន, ពេញព្រៀប ។

ក្រៅពីនេះ សុទ្ធតែជាអក្សរ ប៉ ទាំងអស់ ។

---

ឃ នឹង ភ ផ្សំជាមួយស្រៈ -ឿ-ៀ

ភ មានតែ ៧ ពាក្យប៉ុណ្ណោះគឺៈ

ភ្លឿន (ភ្លើ), ភៀសខ្លួន, ភ្ជួរស្រែ, ភ្ញៀវឬផ្ញៀវ, ភ្លុត ឬផ្លុត (គុម្ព, សំណុំ, កំភួន), ដំរីភ្លៀក, ភ្លៀនឬ ផ្លៀន ។

ក្រៅពីនេះ សុទ្ធតែជាអក្សរ ឃ ទាំងអស់ ។

# ការហាត់សាឡើងវិញ

ចូរកែពាក្យខាងក្រោមនេះ  តាមការសង្កេតដែលបាន សិក្សារួចមកហើយ ៖

| ពាក្យខុស | ពាក្យត្រូវ |
|---|---|
| អិតនេះមានពណ៌ដូចអិន្ទុះន្ទូ ។ | |
| ក្នងអិុងលោកយើង អិតមានអ្នក | |
| មានអិុទ្ធានុភាពណាម្នាក់  អាច | |
| ផ្ចាញ់ទីងមរណៈភាពបានទេ ។ | |
| សម្ដេចព្រះអុិបៈយុវៈពជទ្រង់ | |
| ជា•ទាហរណ៍ ដ៏អុិត្តមដល់សទ្ធិ- | |
| ភាពសាកលលោក ។ | |
| លឺថា អូវពុកចៅកមានរឹគពា | |
| ដូចជាតារីស័មែនរឺទេ? - ខ្ញុំដូចជា | |
| មិនដែលលឺដែរ ។ ពេលយប់ | |
| ងងិតងិតមាត់ស្ទឹង ខ្យល់បកវិង ។ | |

ទិសខាងលិច រលកខ្សោលៗ
ពោលហក់ហឹប អង្គុយបន្តឹប
ស្រឹបៗភ្លៀង ៗ ស្ទុកព្រិកក្រុំ
ទងធ្លាក់ប៉ើលប៉ាលដល់ដី ជន
អ្នកមានភ្នែកសុក្រិត អាចយក
មកធ្វើជាឧទាហរណ៍ក្នុងប្រស្នា
ជីវិត ៗ

គួរឬ? បើស្រុកកើតទុក្ខ
ហើយខ្លះនាំគ្នាតួញយំ, ខ្លះច្រៀង
រាំ, ខ្លះភៀសខ្លួនលែងឲ្យជួប
គ្នាយ៉ាងនេះ ៗ

# ពាក្យពិបាក

## ដែលទាក់ទងដោយព្យញ្ជនៈ

### ក្មេង ឬ ខ្មេង?

យើងដឹងហើយថា ដើង ្អ, ្ហ, ្ម, ្យ, ្ល, ្វ ទាំង ៦ តួនេះ អាចយកទៅផ្ញើជាមួយ ក និង ខ បានដូចគ្នា, កាលណាអានទៅ គេឮសូរស្រដៀង ៗ គ្នា ជាហេតុនាំឲ្យអ្នកសរសេរពោរកែបែកគំនិតមិនដឹងជាសរសេរតួណាមួយ ៗ ដើម្បីធ្វើការជាក់ស្ដាប់ក្នុងចិត្ត គប្បីអ្នកសិក្សាចំណាំពាក្យជាក្រុម ៗ នេះតទៅ៖

### ក ឬ ខ?

ក្អ មានតែ ៥ ពាក្យប៉ុណ្ណោះគឺ:

ក្អក, ក្អាញ់, ក្អិកក្អក ឬ ក្អកក្អិក, ក្អិច, ក្អួន ៗ

ក្រៅពីនេះ ត្រូវសរសេរ ខ្អ ទាំងអស់ ៗ

ក្ម មានតែបីពាក្យប៉ុណ្ណោះគឺ:

ក្មេងក្មាង, កូនក្មួយ, ម្ដាយក្មេក ។

ក្រៅពីនេះ ត្រូវសរសេរជា ក្ម ទាំងអស់ ។

---

ក្ល មាន ៣២ ពាក្យគឺ:

ពេកក្លន, ក្លងប្រាក់, បាំងក្លស់, ក្លាក់ប៉ារី, ក្លាហាន, ក្លាក់ខៀន, ក្លាក់ម្ហុល, ក្លាត់បោរ, ក្លែងក្លាយ, ក្លារពោស, ម្ហុលក្លាស់, ប្រទេសក្លឹង្គ, ក្លិង្គ្រាស្រ, ធុំក្លិន, ក្លឹងរទូត, (បង ឥតគំទ្វប), សត្វក្លស, អម្បោះក្លុក, ក្លីម្រោក, ដំរីក្លៀក, ពោមក្លៀក, ក្លៀវក្លា, ដើរក្លៅក្លម (គឺដើរបញ្ចុះបញ្ចូលគ្ន បទអាក្រក់), ក្លែងរូប, ក្លែបខ្ទុរ, ក្លែមស្រា, ក្លោងទ្វារ, មូលក្លុំ, ផតក្លុំ, បានក្លាំ, ត្រីក្លាំងហាយ, ដើមក្លាំពាក់, ដើមក្លាំពូ ។

ក្រៅពីនេះត្រូវសរសេរជា ក្ល ទាំងអស់ ។

---

ក្ស មាន ៨ ពាក្យគឺ:

ក្សត្រ ឬ ក្សត្រិយ៍, ក្ស័យជីវិត, ក្សាន្តចិត្ត, ក្សណៈនោះ, ក្សណក្ស័យ, ក្សីរ, ក្សេត្រាធិការ, ក្សេមក្សាន្ត ។

ក្រៅពីនេះ ត្រូវសរសេរជា ខ្ស ទាំងអស់ ។

---

ក្អ មានតែមួយពាក្យគឺ:

ដើមក្អម្ព (ក្អំ) ។

ក្រៅពីនេះត្រូវសរសេរជា ខ្អ ទាំងអស់ ។

---

ក្វ មានតែមួយពាក្យគឺ:

ក្វៃន (ប្រសប់, ស្ទាត់, ជំនាញ) ។

ក្រៅពីនេះត្រូវសរសេរជា ខ្វ ទាំងអស់ ។

ចំណាំ.– ១ ជើង ្ប ផ្ញើជើងបានតែនឹង តួ ក មួយ ប៉ុណ្ណោះ មិនអាចផ្ញើនឹង ខ បានទេ ដូចជា ក្បាល, ក្បោះ

ក្បាយ, ដោះក្បំ ។ល។

២- ចំណែកជើង ្យ ធ្វើបានតែជាមួយតួ ខ ប៉ុណ្ណោះ មិនអាចធ្វើជើងទឹង ក៏ បានទេ ដូចជា៖

ខ្យង, ខ្យល់, ខ្យាដំរី ។ល។

---

## ត ឬ ដ?

ព្យញ្ជនៈពីរនេះមានធ្វើជើង៤គឺជើង ្យ, ្ន, ្ម, ្វ ។

ត្ន មានតែមួយពាក្យប៉ុណ្ណោះគឺ៖

ដើមត្នោត

ក្រៅពីនេះត្រូវសរសេរជា ដ្ន ទាំងអស់ ។

ត្ម មាន៦ពាក្យគឺ៖

អាត្មា, សត្វត្មាត, ដួលត្មិល, វាយមួយត្មោង, ផួល ត្មោល, ត្មះតិះដៀល ។

ក្រៅពីនេះត្រូវសរសេរជា ដ្ម ទាំងអស់ ។

---

ត្ល មាន៩ពាក្យគឺ:

វាលត្លឹង, ត្លុករបាំ, ក្របត្លុង, មូលត្លុំ, សត្លត្លុម, ស្រឡះត្លេរ, លៀនត្លៃ, ក្រហមត្លែត, ក្អែកត្លោត ។

ក្រៅពីនេះ ត្រូវសរសេរជា ទ្ល ទាំងអស់ ។

ចំណាំ.- ១ ជើង ្ល ប្រើបានតែជាមួយ ត (ត្ល) មួយប៉ុណ្ណោះ មិនអាចប្រើជាមួយ ទ បានទេ ។

២- ជើង ្អ ក៏ប្រើបានតែជាមួយនឹង ត ដែរ មិនអាចប្រើជាមួយ ទ បានទេ ។

---

ប ឬ ផ?

ព្យញ្ជនៈពីរតួនេះ មានអក្សរផ្ញើជើងពីរតួគឺ ្ត - ្ដ ។

ប្ត មានតែ ៤ ពាក្យគឺ:

ប្តីប្រពន្ធ, ប្តឹងផ្តល់, ប្តូរជីវិត, ប្តេជ្ញា ។

ក្រៅពីនេះ ត្រូវសរសេរជា ផ្ត ទាំងអស់ ។

---

ប្ល មាន ៣២ ពាក្យ គឺ:

ប្លក់, ប្លត, ចោរលួចប្លន់, ប្លប់ឬផ្លប់, ប្លម, ប្លាច់, ប្លាញ, ប្លាត, ត្រើប្លាឆ្ង, ប្លាច់ឬផ្លាច, ប្លាយ, ប្លិកៗឬប្លឹកៗ, ប្លិន, ប្លឹម, ប្លុក, ប្លុង, ប្លុងៗ, ប្លូនឬផ្លូន, ប្លួកឬផ្លួក, ប្លើះៗ, ប្លៀកៗ, ប្លៀវ, ប្លេងប្លោង, ប្លេះប្លោះ, ប្លែកប្លែង, ប្លែមឬព្លែមៗ, ប្លោក, ប្លោង, ប្លោញៗ, ប្លោតឬផ្លោត, ប្លាំៗ

ក្រៅពីនេះ ត្រូវសរសេរជា ប្ល ទាំងអស់ ។

ចំណាំ.- ដើម ្អ ផ្ញើដើមទីង ប្ល មានតែពីរពាក្យ គឺ ប្អូន, ប្អឹះ ឬព្អឹះ ។

ក្រៅពីនេះ ដើម ្យ, ្អ ត្រូវសរសេរជា ប្យ, ប្អ ទាំងអស់ ។

---

## ព ឬ ភ?

ដើម ្យ ប្រកបតែជាមួយទីងព (ព្យ) មួយប៉ុណ្ណោះ

ដូចជា ៖

ព្យាធិ, ព្យាបាល, ព្យាយាម, ខ្យល់ព្យុះ, ព្យួរ, ព្យញ្ជនៈ, ព្យាង្គ ។ល។

ឯជើង ្ជ ត្រូវប្រកបជាមួយតួ ភ (ភ្ជ) វិញ មិនអាចប្រកបនឹង ព បានទេ ដូចជា ភ្ជួរស្រែ, ភ្ជិត, ភ្ជុំ, ភ្ជាំ ។ល។

---

## ពិ ឬ ពី?

ជាញឹកញយណាស់ ដែលអ្នកសិក្សាច្រឡំពាក្យពីរម៉ាត់នេះ ។ ចូរធ្វើការសង្កេតដូចតទៅ ៖

### ពិ

ពាក្យដែលមាន ពិ នៅខាងដើម ច្រើនតែក្លាយមកពីបាលីឬសំស្ក្រឹត ដែលមានរូបស័ព្ទដើមជា វិ (ផ្លាស់ វ ជា ព)

ពាក្យដែលធ្លាប់ប្រើ

ពិចារណា, ពិគ្រោះ, ពិបាក, ពិនិត្យ, ពិនិស្ច័យ,

ពិឃាត, ពិការ, ពិចិត្រ, ពិន័យ, ពិតាន, ពិសាខ, ពិធី, ពិសោធ, ពិពេធ, ពិទ័គ្ធ, ពិទូរ្យ, ពិទុ, ពិទ្យាធរ, ពិជ័យ, ពិដិតមារ, ពិពិធភ័ណ្ឌ, ពិណ, ពិណពាទ្យ, ពិផាត, ពិពន្ល្យសប្ចា ឬ ពិភទ្ទសប្ចា, ពិភ័ក្តិ, ពិពណ៌នា, បុណ្យពិ-ព័រណ៌, ពិព្យាយាម, ពិភាក្សា, ពិមល, ពិមាន, ពិម្ពា, ពិពល័យ, ព្រះពិរុណ, ពិរុឡ្ហ, ពិភព, ពិទ្យា, ពិស, ពិស្ណុការ, ពិសេស, ពិសម័យ, ពិសិដ្ឋ, ពិសុទ្ធ, ពិស្តារ ។

## ពាក្យខ្មែរសុទ្ធមានប្រើដោយតិច

ពិដោរ (ក្លិន), ពិត, ពិតពិល, ពិន (ស្មៀតសក់ ឬ ថែបហាលថ្នាំ), ត្រីពិន្ទុង៍, ពិល, ពិលាប (ខ្សឹកខ្សួល ឬ ឈ្មោះភ្លេងមួយបទ) ។

# ពី

ច្រើនប្រើចំពោះតែពាក្យខ្មែរសុទ្ធប៉ុណ្ណោះ ហើយមាន
ដោយគិតគូរ ៖

មកពីណា ?, ធ្វើពីអ្វី?, អំពី, ពីព្រោះ, ពីរោះ,
ពីង (ចូង), ពីងពង់, ពីងពាង, ពីងពាំង, ពីមពើម, ពីរបី ។

ចំណាំ.- ពាក្យដាក់បានពីរយ៉ាងគឺ ៖

ពិសា ឬ ពីសា, ពិសី ឬ ពីសី ។

# ការហាត់សាឡើងវិញ

ចូរកែពាក្យខាងក្រោម តាមការចំណាំដែលបានសិក្សារួចមកហើយ

| ពាក្យខុស | ពាក្យត្រូវ |
| --- | --- |
| ខ្មេងក្មេរសព្វថ្ងៃ ចិត្តខ្លាហានប្រៃ | |
| មិនបេះខ្វិកក្អក់ ធ្វើឫកឡៀវខ្វា មិន | |
| មានគក់ម៉ក់ ផ្លាស់ចិត្តអាក្រក់ ក្រក្វក់ | |
| បោលអស់ ។ | |
| ចោរលួចចោរផ្លន់ចិត្តមិនគួប អា | |
| ចោរខិលខូចលួចទាំងថ្ងៃ អាបើបាប់ | |
| បានមុខងាខ្វ័យ យីអាចង្រៃ | |
| ប្លោះផ្លោងផ្ទូប ! ។ | |
| ផ្លូនណាមិនធ្វើឲ្យបងតឹងចិត្តភ្លឺះប្អូន | |
| នោះប្រាកដជាផ្លូនរបស់បង ! ។ | |
| បុណ្យពីព័រណណ៍ល្អពិចិត្រ ផ្សិត | |
| ពីសេស អ្នកណាអេះ បេះតាក់តែង | |
| ស្តែងរបនា គិតពីសោធយ៉ាងពីសុទ្ធ | |
| ផុតពីការណ៍ គួរទស្សនាយក | |
| ទស្សនះដាក់ក្នុងខ្លួន ។ | |
| ហៃកែវពីសី ពិព្រោះហេតុអ្វី បាន | |
| ដាពីលាប ? | |

# ពាក្យពិបាក

## ដែលទាក់ទងដោយសព្ទវេយ្យាករណ៍

### នូវ ឬ នៅ?

ខ្ញុំតែងឃើញអ្នកសិក្សាខ្លះ សរសេរច្រឡំពាក្យជាវេវចនៈនេះ ។ កំហុសនេះ កើតមកពីការយល់មិនច្បាស់នូវអត្ថន័យរបស់ពាក្យ ។ ឲ្យអ្នកសិក្សាប្រើការសង្កេតតាមវិធីខាងក្រោមនេះ៖

### នូវ

ជាអាយតនិបាតទី២ បង្អុលសេចក្ដីឆ្ពោះទៅរកកម្មរង (complément direct) ។ ប្រើបានតែជាមួយនឹងសកម្មកិរិយា (verbe transitif) ប៉ុណ្ណោះ ។

ឃ្លាដែលគេធ្លាប់ប្រើ

ខ្ញុំសូមថ្លែងនូវអំណរគុណដ៏ជ្រាលជ្រៅចំពោះលោក ។

សូមលោកទទួលនូវសេចក្ដីរាប់អានដ៏ស្មោះអំពីខ្ញុំ ។

ខ្ញុំសូមថ្លែងនូវសេចក្ដីសរសើរជាអនេកចំពោះលោក ។

ខ្ញុំសូមផ្ញើជាប់មកជាមួយនេះនូវបញ្ជីរាយនាមពីរច្បាប់ ។

សូមលោកទទួលនូវប្រាក់ចំនួន ១០០០ រៀលអំពីខ្ញុំ ។

សូមលោកទទួលនូវកតញ្ញុតា នឹងមេត្រីភាពអំពីខ្ញុំ ។

សិស្សណាមានព្យាយាម សិស្សនោះគង់បានទទួលនូវលទ្ធផល ជាទីគាប់ចិត្តមិនខាន ។

ចំណាំ.— កាលណាមានប្រយោគដូច្នេះ ត្រូវធ្វើសំនួរក្នុងចិត្តថា : អ្វី ? ធ្វើអ្វី? ឲ្យអ្វី? ទទួលអ្វី?

វិធីប្រើពាក្យ «នូវ».— ខ្មែរយើងនិយមប្រើពាក្យ «នូវ» នេះ ដោយយកលំនាំតាមការបកប្រែផ្ទាល់នៃភាសាបាលី ត្រង់អាយតនិបាតទី២ (ំ=ប្រែថានូវ...) ។ ដូចជា «បុគ្គលោ រីបុគ្គល, ករោតិ ធ្វើ, បាបំ នូវបាប» ។ ការបកប្រែផ្ទាល់ពីភាសាបាលីមកជាខ្មែរបើមានកម្ម (complément)

ទទួលសកម្មកិរិយា តែមិនប្រែថា «នូវ» ជាដរាប តែវេលាប្រែយកសេចក្ដីវិញ លោកតែងកាត់ចោលខ្លះ ៗ ចំពោះភាសាខ្មែរយើងក៏ច្រើននិយមតាមភាសាបាលីដែរ ហើយយកមកប្រើជាញឹកញយ ។ តែការប្រើនេះ, ក្រៅពីការថ្លែងសុន្ទរកថា ឬ បាឋកថា ឬ កំណើតសន្និសីទ, ខ្មែរយើងមិននិយមប្រើក្នុងភាសានិយាយធម្មតាផងទេ គេប្រើតែក្នុងភាសាសរសេរប៉ុណ្ណោះ ៗ ក្នុងភាសាសរសេរនេះទៀតសោត ក៏គេមិនមែនចេះតែប្រើគ្រប់តែពាក្យ សាមញ្ញទាំងអស់នោះទេ គេច្រើនប្រើតែប្រយោគណាដែលមានសកម្មភាពថ្លៃថ្នូរ (ដូចឃ្លាខាងដើម)ប៉ុណ្ណោះ ៗ

គេមិនដែលសរសេរថា:

«ខ្ញុំទទួលទាននូវបាយ, ផឹកនូវទឹកតក, ពាក់នូវធ្មេញ, ជក់នូវបារី រួចទៅធ្វើនូវការ» ដូច្នេះទេ ៗ

## ដោយនូវ (ដោយសារ)

ជាអាយតនិបាតទី ៣ ។ គេច្រើនប្រើក្នុងសព្ទសាសនា ដែលមានន័យថា «ដោយសារ» ឬក្នុងទីបញ្ចប់នៃប្រយោគបូកណា ដែលមានន័យថា «ដល់» ។

១. ព្រះពុទ្ធទ្រង់រឿងដោយនូវ តេជ: ។

– ក៏ចប់បរិបូណ៌សមគួរ ដោយនូវវេលានេះឯងហោង ។

ចំណាំ. – កាលណាមានប្រយោគ ដែលមានពាក្យ ដោយ នៅខាងដើមដូច្នេះ ត្រូវធ្វើសំនួរក្នុងចិត្តថា: ដោយសារអ្វី? ដល់អ្វី? ។

---

## នូវ (ហើយនឹង, ព្រមទាំង)

ជានិបាតសព្ទ ។ គេច្រើនឃើញនូវជានិបាតសព្ទខ្លះ ក្នុងប្រយោគបូកណា និយាយពីការរៀបរាប់ឈ្មោះព្រឹក្សា, សត្វ

ទីង៖ឈ្មោះនាម៉ឺនមុខមន្ត្រី ដែលមានន័យថា «ហើយទីង, ព្រមទាំង» ៖

១. គតីខ្លុងត្បែង នូវធ្មុកស្រុក ។ល។,
សត្វបក្សាបក្សី នូវអស់ម្រឹគីម្រឹគា ។ល។,
ព្រះពជវង្សានុវង្ស នូវអស់នាម៉ឺនសព្វមុខមន្ត្រី ចៅជិត ចៅចម ដំណាវខុនណាង ។ល។

ចំណាំ .– កាលណាមានប្រយោគដូច្នោះ ត្រូវធ្វើសំនួរកង់ចិត្តថា ហើយទីងអ្វី? ព្រមទាំងអ្វី? ។

---

...ងទៅគ្រូ (ដោយ)

គេច្រើនឃើញក្នុងប្រយោគបុរាណនិយាយពីការរៀបរាប់ឈ្មោះវត្ថុ, ព្រឹក្សា ឬពីការលាយឡំដោយវត្ថុមួយក្នុងចំណោមវត្ថុច្រើន ដែលមានន័យថា «ដោយ» ៖

១. គ្រាលទីទៅនូវកម្រាលចៀមចំព្រែព្រំ ។ល។

– ដំប្រដាប់នីទៅនូវឈើផងតាំងឡាយដំរិចគ្រនូវផ្លែផ្កានោះផ្សេង ៗ ដំប្រកបនីទៅនូវបេកស្នែង បេកដង ខ្វែង ៗលៗ

– ចៅបេតបុត្រ លុះឮមាត់តាជូជកទ្រហោយំ ប្រឡំនីទៅនូវសំឡេងឆ្កែព្រុស ៗលៗ

ចំណាំ.– « នូវ » ក្នុងប្រយោគដូចខាងលើនេះ តែងមានពាក្យ « នីទៅ » នៅជាប់ពីខាងដើមជាដរាប ទុកជាគ្រឿងសំគាល់ដល់អ្នកសិក្សាយ៉ាងងាយ ៗ គប្បីអ្នកសិក្សាធ្វើសំនួរក្នុងចិត្តថា នីទៅដោយអ្វី ?

---

## ទៅ

ជាកិរិយាស័ព្ទ បង្អុលសេចក្តីឆ្ពោះទៅរកកម្ម ជាទីកន្លែងទីនិងពេលវេលា (complément de lieu et de temps) ៗ ប្រើបានចំពោះតែកម្មជាទីកន្លែងទីនិងពេលវេលាប៉ុណ្ណោះ ៖

១. កុមារនេះ កាលដើមឡើយមានស្រុកកំណើតនៅព្រៃវែង ឥឡូវនេះមករៀននៅវិទ្យាល័យស៊ីសុវត្ថិក្រុងភ្នំពេញ ។

– នៅពេលមានអគ្គិភ័យម្ដងៗ មនុស្សឥតទីលំនៅតែងបានទទួលនូវព្រះរាជអំណោយអំពីព្រះបិតាឯករាជ្យ ។

ចំណាំ.– កាលណាមានប្រយោគដូច្នេះ ត្រូវធ្វើសំនួរក្នុងចិត្តថា: ឯណា ? ទីណា ? ពេលណា ? ក្នុងអ្វី? ពេលអ្វី?

## ការប្រែប្រួលរវាងគុណនាមនឹងនាម

មានពាក្យខ្លះ ដែលក្លាយមកពីបាលីនិងសំស្ក្រឹតរមែងផ្លាស់ប្ដូរជានិច្ច រវាងនាមនិងគុណនាម ។ ពាក្យទាំងនោះមានប្រើដោយតិចបំផុតក្នុងភាសាខ្មែរ ។

## ពាក្យដែលធ្លាប់ប្រើ

| គុណនាម | ប្រែប្រួលទៅជា | នាម |
| --- | --- | --- |
| អព្យាក្រឹត (neutre) | „ | អព្យាក្រឹត្យ, អព្យាក្រឹតភាព (neutralité) |
| ឯករាជ (Indépandant) | „ | ឯករាជ្យ, ឯករាជភាព (Indépendance) |

១. គុ. កម្ពុជា ជាប្រទេសប្រកាន់នយោបាយអព្យាក្រឹត ។ ប្រទេសអព្យាក្រឹតអាចធ្វើឲ្យមានសេចក្ដីសុខសាន្តដល់សកលលោក ។ ន. អព្យាក្រឹត្យ នៃប្រទេសខ្មែរជាកំឡាំងដល់សន្តិភាពក្នុងលោក ។

១. គុ. ប្រទេសឯករាជ ។ កម្ពុជា ជាប្រទេសឯករាជ-អព្យាក្រឹត ។ ន. ឯករាជ្យនៃប្រទេសខ្មែរបានមកដោយសារព្រះហស្តនៃសម្ដេចព្រះនរោត្តម-សីហនុ ព្រោះហេតុនោះ ទើបប្រជាជនខ្មែរថ្វាយនាមព្រះអង្គថា “ព្រះបិតាឯករាជ្យជាតិ„ ។

ចំណាំ - កុំប្រើ «ព្រះបិតាឯករាជ្យ» ជានាម ព្រោះគេអាចនិយាយថា «ព្រះបិតានៃឯករាជ្យ» (Père de l'Indépendance) ។

---

## ការប្រែប្រួលរវាងកិរិយានិងនាម

ក្នុងភាសាខ្មែរ គេសង្កេតឃើញថា មានពាក្យខ្លះដែលក្លាយមកពីបាលីនិងសំស្ក្រឹត តែងមានការប្រែប្រួលជានិច្ច ។ ចំពោះពាក្យខ្មែរសុទ្ធ មិនមានការប្រែប្រួលទេ ។

### ពាក្យដែលធ្លាប់ប្រើ

| កិរិយា | ប្រែប្រួលទៅជា | នាម |
|---|---|---|
| ច្បុត | » | ការច្យុតិ |
| និមន្ត | » | ការនិមន្តន៍ |
| បដិវត្ត | » | ការបដិវត្តន៍ |
| ប្រព្រឹត្ត | » | ការប្រព្រឹត្តិ |
| បរិសុទ្ធ | » | សេចក្តីបរិសុទ្ធិ |

| | | |
|---|---|---|
| បញ្ញត្ត | ប្រែប្រួលទៅជា | សេចក្ដីបញ្ញត្តិ |
| ប្រសូត | " | ការប្រសូតិ |
| ប្រវត្ត | " | ការប្រវត្តន៍ |
| ពិសោធ | " | ការពិសោធន៍ |
| វិវឌ្ឍ | " | ការវិវឌ្ឍន៍ |
| អនុវត្ត | " | ការអនុវត្តន៍ |
| អនុញ្ញាត | " | សេចក្ដីអនុញ្ញាតិ |
| សន្មត | " | សេចក្ដីសន្មតិ |

ចំណាំ.- ដើម្បីសំគាល់ឲ្យដឹងថាពាក្យទាំងនោះជា នាម ខ្ញុំយើងតែងដាក់សព្ទថា ការ, សេចក្ដី, ដំណើរ, កិរិយា នៅពីខាងដើមពាក្យទាំងនោះ (ការអនុវត្តន៍) ។ ឯសព្ទដែលគេប្រើញឹកញាប់គឺ ការ, សេចក្ដី ។ ដូច្នេះគប្បីអ្នកសិក្សាតាមសង្កេតមើល បើកាលណាឮសព្ទទាំងនេះនៅខាងដើមពាក្យទាំងនោះប្រាកដជានាមហើយ ។

# ការហាត់សាឡើងវិញ

ចូរកែពាក្យខាងក្រោមនេះ តាមការបង្កេតដែលបានសិក្សារួចមកហើយ

| ពាក្យខុស | ពាក្យត្រូវ |
| --- | --- |
| សូមលោកទទួលនៅអំណរគុណផាមុន ព្រមទាំងសេចក្ដីរាប់អានដ៏ស្មោះអំពីខ្ញុំ ។ | |
| ព្រលឹមឡើង ផ្សារថ្មីគេឃើញមនុស្សប្រុសស្រីនៅក្មេងតូចធំ ដើរអ៊ូអរបុះឡើង ខ្វះមានកាន់នូវដៃ នោកញ្ចប់តូចធំនំនែក ដើម្បីយកទៅបែកឈាយអ្នកនូវផ្ទះ ។ | |
| សម្ដេចព្រះបិតាឯករាជជាតិ ទ្រង់ដឹកនាំនាវិអព្យាក្រឹត្យ ឆ្ពោះទៅកាន់ត្រើយសន្តិភាព ។ | |
| ការអនុវត្តមាគ៌ាអព្យាក្រឹត្យ នាំឲ្យនាវិកម្ពុជាឃ្លេងឃ្លោងអន្តអក្កាល ព្រោះតែការប្រព្រឹត្តអំពើស្មោកគ្រោកនៃជនអ្នកនៅជិតខាង ។ | |

# ពាក្យពិបាក

## ដែលទាក់ទងដោយសទិសស័ព្ទ

ដូចអ្នកសិក្សាបានដឹងមកហើយថា «ការសិក្សាអនុពាក្យ» ជាដំបូង គេងសិក្សាអំពីការអានឲ្យត្រឹមត្រូវនឹងការសរសេរត្រូវអក្សរឲ្យបានច្បាស់លាស់តាមអក្ខរវិធី, ជាបន្ទាប់ គេងសិក្សាអំពីពាក្យពិបាកដែលទាក់ទងដោយវណ្ណយុត្តិខ្ទះ, ដោយស្រៈពេញតួ, ដោយស្រៈទិសង្ស័យ, ដោយព្យញ្ជនៈ នឹងដោយស័ព្ទវេយ្យាករណ៍ ឃើញថា «ការសិក្សាអនុពាក្យ» យើង មានគ្រឿងឧបករណ៍ស្ទើរតែគ្រប់គ្រាន់ដែរហើយ ប៉ុន្តែខ្ញុំសង្កេតឃើញនៅមាន «ពាក្យពិបាកដែលទាក់ទងដោយសទិសស័ព្ទ» មួយទៀត ដែលតែងធ្វើកិច្ចកលនាំឲ្យអ្នកសិក្សាក៏ខ្ទម្ទង ៗ ស្ទើរតែគេចពីកំហុសមិនរួច ពីព្រោះក្នុងភាសាខ្មែរយើងក៏ដូចជាភាសាបារាំងដែរ គឺមានពាក្យច្រើនណាស់ដែលអានដូច ៗ គ្នា

តែបែរជាមានន័យផ្សេងគ្នាទៅវិញ ។

ហេតុនេះ បើចង់ជៀសវាងកុំឲ្យមានការស្ទាក់ស្ទើរចិត្ត ឬក៏ឆ្ងល់ប្រឡំតទៅទៀត គប្បីអ្នកសិក្សាឆ្លៀតពេលសង្កេត-ពិនិត្យ - ចំណាំនូវសទិសស័ព្ទទាំងនេះ ឲ្យបានជាក់ច្បាស់ក្នុងចិត្តដូចតទៅ ៖

សទិសស័ព្ទក្នុងព្យញ្ជនៈ «ក»

ក. ន. កមនុស្ស

ក៏ និ. អ្នកក៏ដោយ

ករ ន.ដៃ: លើកករប្រណម្យ

ករ ន. កម្មករ, ពលករ, វិស្វករ, ឃាតករ, ផាតុករ, វិចិត្រករ, កសិករ, និករ, និសាករ (ព្រះចន្ទ), មករ, ទុស្សាហករ, ហត្ថករ ។

ករណ៍ ន. ឧបករណ៍, វេយ្យាករណ៍, អធិករណ៍, ខេត្តុប្បករណ៍, សិក្ខូប-ករណ៍, នេសាទុប្បករណ៍, សហករណ៍ ។

កករ ន. កករទឹក ។

កណ្ឌ ន. សាស្ត្រាមួយកណ្ឌ

កន្ទះ គុ. កន្ទះពោធិ៍

កាប ន. កាបរទេះ

កប្ប ន. មួយកប្ប

កម្ម ន. កម្មផល, អំពើ

កល ន. កិច្ចកល, ឧបាយ

កល្ប ន. មួយកល្ប

កាល ន. ពេល

កា ន. បំពង់ដាក់ទឹក

ការ ន. ធ្វើការ, កម្មការ
អធិការ, ពលិការ

កាណ៌ ន. ព្រះកាណ៌
(ត្រចៀក)

កាន់ កិ. កាន់វត្ត

កន្ទាស់ ន. កន្ទាស់ក

កាព្យ ន. ពាក្យកាព្យ

កាប់ កិ. កាប់ចាក់

កាំ ន. កាំជណ្ដើរ

កល់ កិ. កល់កង់ឡាន

កាល់ កិ. គោកាល់ញី

កាឡកណ្ណី ន. មនុស្សចង្រៃ

កា កិ. កាស្រោមសំបុត្រ

ការ ន. ការងារ, ការពារ
លេខាធិការ, ទិន្នាការ

ការណ៍ ន. (ហេតុ) ព្រឹត្តិការណ៍,
គោលការណ៍, អត្ថការណ៍,

ក្រៃ ន. និយាយគេរគេ ក្រៀ ន. ក្រៀមតិក

ក្រោត គ. កោតក្រែង ក្រោដិ ប.ស. ចំនួន ១០ លាន

ក្រោដ្ឋ ន. កោដ្ឋដាក់ធាតុ

ក្រិត គ. ក្រិតចំណាំ ក្រឹត្យ ន. ក្រឹត្យវិន័យ

សទិសសព្ទក្នុងព្យញ្ជនៈ "ខ"

ខណ្ឌ ន. ខេត្តខណ្ឌ, ខណ្ឌសីមា ខន្ធ ន. រលត់ខន្ធ,
ក្រុមខណ្ឌ, ខណ្ឌផញ្ចាំង វិញ្ញាណក្ខន្ធ

ខាន់ ន. ព្រះខាន់

ខ្ញុំ ន. ខ្ញុំការ, ខ្ញុំបម្រើ ខ្ញុំ ន. ខ្ញុំក្បាលមនុស្ស

ខៀវ ន. ខៀវសាំ ខៀរ ន. ស្មាខៀរ

## សទិសស័ព្ទក្នុងព្យញ្ជនៈ «គ»

គ គុ. មនុស្សគថ្លង់ | គរ ន. ដើមគរ, គរជាគំនរ

គណ ន. សិស្សគណ | គន់ កិ. គយគន់

គុណ ន. គុណមាតាបិតា | គុន ន. គុនដាល់

គុំ កិ. គុំរាយគ្នា | គុម្ព ន. គុម្ពឈើ

គូ ន. មាន់មួយគូ(ពីរ) | គូរ កិ. គូរគំនូរ, គិតគូរ

គេ បុ. គេឯង, ពួកគេ | គេហ៍ បុ. ស្ត្រីមេផ្ទះ

(«ឃ» គ្មានសទិសស័ព្ទទេ)

## សទិសស័ព្ទក្នុងព្យញ្ជនៈ «ង»

ង គុ. ទូកង | ងរ កិ. ងរចុះងរឡើង

ងា កិ. ងាដៃជើង | ងារ ន. ការងារ, ដីមួយងារ

## សទិសស័ព្ទក្នុងព្យញ្ជនៈ «ច»

ច ន. ឆ្នាំច

ចក្រ ន. ចក្រយាន, ពេជ្រ ចក្រ, អាណាចក្រ, ពុទ្ធចក្រ,

ចណ្ឌ គុ. ប្រច័ណ្ឌ

ចន្ទន៍ ន. ខ្លឹមចន្ទន៍

ចារ ន. ផ្កាចារ

ចារ្យ ន. អាចារ្យ, អនាចារ្យ អស្ចារ្យ, ព្រឹទ្ធាចារ្យ

ចិត កិ. ចិតបន្លែ

ចិត្រ ន. ចិត្រមូលភ្លើង, វិចិត្រ

ចរ កិ. ត្រាច់ចរ, គោចរ, ចរាចរ

ចាក់ កិ. ចាក់ទឹក, ចាក់សម្រាម, មនុស្សចាក់គ្នា

ចន្ទ ន. ព្រះចន្ទ

...ច័ន ន. ទំច័ក្កច័ន

ចារ កិ. ចារសាស្ត្រា

ចារុ៍ ន. ពាក់ចារុ៍, ចារុ៍មាស - ចារុ៍ប្រាក់

ចិត្ត ន. ចិត្តល្អអាក្រក់

ចោត គុ. ច្រាំងទន្លេចោត  ចោទ្យ ន. ពោទឡើយ

ច្បា ន. ផ្កាច្បាឥតក្លិន  ច្បារ ន. សួនច្បារ,

### សទិសស័ព្ទក្នុងព្យញ្ជនៈ «ឆ»

ឆន្ទ ន. កាព្យឆន្ទ  ឆាន់ កិ. និមន្តលោកឆាន់

ឆ្មា ន. សត្វឆ្មា  ឆ្មារ គុ. សរសៃឆ្មារ, តូចឆ្មារ

### សទិសស័ព្ទក្នុងព្យញ្ជនៈ «ជ»

ជន ន. នរជន  ជន់ កិ. ទឹកជន់លិច

ជន្ម ន. ព្រះជន្ម

ជាត គុ. ដែលកើតហើយ  ជាតិ ន. ជាតិខ្មែរ

ជ្ជិ គុ. មនុស្សជួជាតិ    ជ្ជិរ ន. ឈរជាជួរ, ជួរខាងម្ដាយ

ជ្ជុំ កិ. វិ. មួយជុំ    ជ្ជិំ ន. ជំនុំជំរះ, ជំនះ

## (“ឈ, ញ„ គ្មានសទិសស័ព្ទទេ)

### សទិសស័ព្ទក្នុងព្យញ្ជនៈ «ដ»

ឌ ន. កំពង់ដ, ទូកដ    ឌរ គុ. ដំបៅដរ, បួសដរ

ឌ៏ និ. ដ៏ប្រសើរ

ឌា ន. ថ្នា (ថ្នំ)    ឌារ ន. ធ្វើបុណ្យដារ

ឌុស កិ. ធ្វើឲ្យជ្រះ=ដុសធ្មេញ, ដុសខាត់, ដុសខោអាវ    ឌុះ កិ. ធ្វើឲ្យច្រើនឡើង=ស្រូវដុះ, ពោះដុះ, ដីដុះ

## (ឋ, ឌ, ឍ, ណ, ត, ថ គ្មានសទិសស័ព្ទទេ)

### សទិសស័ព្ទក្នុងព្យញ្ជនៈ «ទ»

ទ្ធ ន. ទឹកហូរតាមទ    ទ្ធរ កិ. (ពាក្យជេរ)

ទន្ត ន. ព្រះទន្ត (ធ្មេញ)

ទាន់ និ. ដើរទាន់

ទា ន. សត្វទា

ទារ កិ. ទារថ្លៃផ្ទះ

ទាល់ ន. ដើមទាល់, ទាល់ប្រក

ទ័ល គុ. ទ័លក្រ, អ្នកទ័លក្រ

ទុក កិ. ទុកដាក់, ទុកចិត្ត

ទុក្ខ ន. កើតទុក្ខ, ទុក្ខវេទនា

ទូ ន. ទូដាក់ខោអាវ

ទូរ កិ. ទូរទាត់, ទូរគ្នា, ទូរស័ព្ទ

ទោស ន. គុណទោស

ទោះ និ. ទោះជាយ៉ាងណាក៏ដោយ

ទុំ គុ. ផ្លែឈើទុំ, ចាស់ទុំ

ទំ កិ. សត្វទំលើមែកឈើ

## សទិសស័ព្ទក្នុងព្យញ្ជនៈ "ធ"

ធន ន. ធនធាន, ទ្រព្យធន

ធន់ កិ. ធន់ទ្រាំ, អត់ធន់

ជុន ន. មនុស្សមួយជុន
បានមួយជុន

ជុំ កិ. ជុំក្និនក្រអូប　　ជិំ គុ. តូចជំ, ធ្ពុកជំ

## សទិសសព្ទក្នុងព្យញ្ជនៈ «ឈ»

ឈ៎ ! ឧ. ឈុះឈ៎ !　　ឈរ ន. ឈរជន

ឈប់ គុ. ស្នែងក្របីកន្ទប់　　ឈៀ ប.សំ(៩), ឧត្តម, ឧត្តគុណ

ឈ័យ ន. ន័យនៃពាក្យ　　ឈៃ អាទិ. ជនាគារជាតិនៃកម្ពុជា

ឈាជិ ន. នាដករ　　ឈាបិ ន. នាងនាថជីតា

ឈ្វេ អាទិ. បានទទួល
នូវអំណោយ　　ឈ្វេ ទិ. នូវរស់នាម៉ឺនសព្វមុខ
មន្ត្រី

ឌៀ កិ. នៅឯណា?

ឌុះ សព្វ. អ្នកណា នុះ?　　ឌោះ វិ. ស. ផ្ទះនោះ

## សទិសស័ព្ទក្នុងព្យញ្ជនៈ «ប»

បង់ក កិ. បង់កកនៃទ្រង់　　បង្ក កិ. បង្កហេតុ

បត់ កិ. បត់សំពត់　　បទ ន. បទចម្រៀង, ធ្វើបទ

បបិ ន. (ផ្លូវ) ជលបថ

បា បុ. ហៃបាអើយ, គោបុះ មេបា　　បារ កិ. បារកកាយ, បាអង្ករ ពីត្បាល់

បាត ន. បាតឆ្នាំង, បាតដី, បាតខ្ទះ, បាតដៃ, បិណ្ឌបាត　　បាទ ន. (ជើង) ព្រះបាទ, ឆ្លើយបាទ

បាត្រ ន. បាតដែក, គ្របបាត្រ　　បាទុក៍ ន. សុពណ៌បាទុក (ស្បែកជើងមាស)

បាត់ កិ. បាត់អីវ៉ាន់

បិត កិ. បិតឈើសម្រួប

បុស្ស ន. ខែបុស្ស

បួ ន. បង់បួ

បួណ៌ គុ. បរិបួណ៌

ប្រមាទ កិ. ធ្វេសប្រហែស

ប្រយ័ត គុ. កិ. មនុស្សប្រយ័ត, ត្រូវប្រយ័តពាក្យសំដី

ប្រាប កិ. (ធ្វើឲ្យចុះចាញ់) ប្រាបសត្រូវ

ប្រុស បុរិស. ប្រុសស្រី

ប្រោស កិ. ប្រោសសត្វ, ពានប្រោស,

ប័ត្រ ន. សញ្ញាប័ត្រ, វិក័យប័ត្រ

បិទ កិ. បិទទ្វារ, បិទមាត់

ប៉ុះ កិ. ប៉ុះអណ្តាក់, គោប៉ុះ

បួរ កិ. និយាយបួរបាច់

បួព៌ គុ. ទិសបួព៌

ប្រមាថ កិ. មើលងាយ

ប្រយ័ត្ន ន. ការប្រយ័ត្ននាំឲ្យបានសុខ

ប្រាប្ត គុ. (បានសម្រេចហើយ)

ប្រុះ គុ. ភ្លូប្រុះ

ប្រោះ កិ. ប្រោះត្រី, ប្រោះអន្ទង់,

ប្រណិប័តន៍ កិ. ក្រាប ប្រណិប័តន៍ (សំពះ)

ប្រតិបត្តិ កិ. ប្រតិបត្តិតាម, ប្រព្រឹត្តតាម

បញ្ញត្ត កិ. រាជការបញ្ញត្ត

បញ្ញត្តិ ន. សេចក្ដីបញ្ញត្តិ

## សទិសស័ព្ទក្នុងព្យញ្ជនៈ «ផ»

ផ្សា គុ. ក ខ្លោចផ្សា, ឈើផ្សា, ប្រែផ្សាមាត់

ផ្សារ ន. ផ្សារថ្មី, ផ្សារកណ្ដាល

## សទិសស័ព្ទក្នុងព្យញ្ជនៈ «ព»

ព កិ. ពកូន, ពពោះ

ពរ ន. សាធុការពរឆ្នាំថ្មី

ពង់ កិ. ក្ងោកពង់, ពង់ខ្ទុះ

ពង្ស ន. ពូជពង្ស

ពន់ គុ. ពេកពន់, ពន់ប្រមាណ

ពន្ធ ន. បង់ពន្ធ, ប្រពន្ធ

ពស់ ន. សត្វពស់

ពោះ ន. ពោះមនុស្ស

ពស្តុ ន. ពស្ដុតាន៍   ពស្ត្រ ន. ព្រះពស្ត្រ(សំពត់)

ពាត ក.វិ ដាក់ពាត   ពាទ្យ ន. ពិណពាទ្យ

ពាធ ក. ពាធជន្ម, សាពាធ(ឈើ)

ពិ ន. មកពីសាលា   ពីរ ប.សំ. ពីរបី

ពុត ក.ន ធ្វើពុតជាឈឺ, ចេញពុត   ពុទ្ធ ន. ព្រះពុទ្ធ

ពុធ ន. ថ្ងៃពុធ

ពេចន៍ ន. ពាក្យពេចន៍   ពេជ្ឈ ន. ពេជ្ឈឃាត

ពេជ្រ ន. ត្បូងពេជ្រ

ពៃ ន. ល្អីពៃ, ប្រាក់១ពៃ   ពៃរ៍ ន. ពោសពៃរ៍

ពោរ គុ. ពោរពេញ, ពុះពោរ   ពោធិ ន. ដើមពោធិ

ព្រ័ត្រ ន. ព្រ័ត្រព្រោម, កាត់ព្រ័ត្រ   ព្រាត់ ក. ព្រាត់ប្រាស

ព្រោម ន. ស្លាព្រោម   ព្រាហ្មណ៍ ន. ពូជព្រាហ្មណ៍

ព្រឹក ន. ព្រឹកល្ងាច　　ព្រឹក្ស ន. ពោធិព្រឹក្ស ព្រឹក្សព្រៃ, ជម្ពូព្រឹក្ស

ព្រឹត្តិ ន. ការប្រព្រឹត្ត, ប្រែព្រឹត្ត　　ព្រឹទ្ធ គុ. ព្រាហ្មណ៍ព្រឹទ្ធ, ចាស់ព្រឹទ្ធ, ព្រេងព្រឹទ្ធ

### សទិសស័ព្ទក្នុងព្យញ្ជនៈ «ភ»

ភប់ កិ. ភប់ប្រសព្វ, ភប់ភក្ត　　ភព ន. ភពផែនដី, ពិភព

ភ័ក្តិ ន. មិត្តភ័ក្តិ, ស្វាមីភ័ក្តិ　　ភក្ត្រ ន. ព្រះភក្ត្រ (មុខ)

ភ្លក្ស កិ. ភ្លក្សសម្ល　　ភ្លុក ន. ភ្លុកដំរី, ម្រះភ្លុក

### សទិសស័ព្ទក្នុងព្យញ្ជនៈ «ម»

មី ន. តាមី, មីគោក　　មឺរ គុ. មីរមេរមាស

មូល ន. មូលហេតុ, រន្ធន៍មូល

មូល្យ ន. ប្រាក់ខែ, ឈ្នួល (ប្រើក្នុងពាក្យកាព្យបុរាណ)

ម្ល កិ. ម្លមៅ

ម្លូរ ន. ស្រូវម្លូរ, ស្រែម្លូរ

ម្រ័ក្សណ៍ ន. ជ័រម្រ័ក្សណ៍

ម្រាក់ ន. គ្រែម្រាក់

ម៉ដ្ឋ គុ. រាបម៉ដ្ឋ

ហ្មត់ គុ. វិ. ស៊ីហ្មត់, ហ្មត់ហ្មង

## សទិសសព្ទក្នុងព្យញ្ជនៈ "យ"

យល់ កិ. យល់យន់, យល់ចិត្ត

យន្ត ឬ យន្ត្រ ន. រថយន្ត

យា កិ. យាយី (បៀតបៀន)

យារ គុ. (ស្រុងចុះ)

យារ កិ. យារដៃយារជើង

យារ ន. សេកយារ

យាស់ ន. យាស់ជញ្ជាប់ស្លឹកស្រូវ

យះ កិ. ធ្វើឲ្យរយះ

យុក ន. សត្វយុក

យុគ ន. អាយុពិភពលោក

យុត្ត គុ. ត្រឹមត្រូវ    យុត្តិ ន. សេចក្ដីត្រឹមត្រូវ

យុទ្ធ ន. តយុទ្ធ

យោក កិ. ដើរយោកខ្លួន    យោគ ន. ការរួបរួម, ប្រយោគ

យោគ្យ ន. យោគ្យភាព

យៅ ន. ជ័រយៅ    យៅវ៌ គុ. វ័យកំលោះក្រមុំ

យម ន. យមបាល, យមរាជ    យំ កិ. ស្រែកយំ

សទិសសព្ទក្នុងព្យញ្ជនៈ "រ"

រង់ កិ. រង់ចាំ    រង្គ ន. ជ័ររង្គ

រុង កិ. រុងរឿង

រងឹ គុ. ក្ទេងញ្ញាធំ    រង្គុម ន. ព្យួររង្គុមៗរៀយៗ

រដ្ឋ ន. ប្រទេស, ដែន,    រត្ន ន. កែវ, ពេជ្រ, ត្បូង

រត្ត គុ. ពណ៌ក្រហម    រ័តន៍ ឬ រ័ត្ន=ត្រ័យរ័តន៍

រៀប ន. រៀបគ្រឿង, រាជរៀប　　រត់ កិ. រត់លឿន

រុត កិ. រុតត្រី

រស ន. មានរសជាតិ　　រស់ កិ. រស់ស្លាប់

រក្ស កិ. (រក្សា) អនុរក្ស, អនុគ្គរក្ស　　រាក់ គុ. រាក់ជ្រៅ

រាក កិ. ឈឺរាក　　រាគ ន. គ្រឿងរាគ

រាប កិ. ទឹករាបពេញស្រែ　　រាជ ន. រាជសម្បត្តិ

រាជ្យ ន. ឯករាជ្យ

រាប គុ. រាបស្មើ　　រាពណ៍ ន. ព្រះរាពណ៍

រិស្ត ន. ដំណើរគាត្រក់, ឧបាយ　　រិះ កិ. រិះរកឧបាយកល, រិះគិត, អ្នករិះ

រន្ធ ន. (រូង) រន្ធកណ្តុរ　　រុគ ន. ឈ្មោះរក់មហ៊ន

វ្ណា្ណ ន. កិរិយាយំ

វេ កិ. វេក　　　　　　វេហ៍ ន. វេហ៍ពល

រោគ ន. ឈ្មោះឈើ, រោគ　រោគ ន. កើតរោគ

ក្រហម

ឫក ន. ឫកពាមារយាទ　　ឫក្ស ន. ឫក្សពារថ្ងៃខែ

ឫក្សណ៍ ន. ឫក្សណ៍ការណ៍

ឫត ន. សេចក្ដីពិត　　　　ឫទ្ធ គុ. ឫទ្ធខ្លាំងពូកែ

រឹត កិ. រឹតខ្សែ

សទិសស័ព្ទក្នុងព្យញ្ជនៈ «ល»

ល័ក្ក ន. ល័ក្កពាន់　　　លក្ខលក្ស ន. សេចក្ដីកំណត់

ល័ក្តល័ខ ន. ល័ក្តក្រហម　លាក់ កិ. លាក់ឈើ

លក្ខណ៍=ស្រីគ្រប់លក្ខណ៍　លក្ស្មណ៍ ន. ព្រះរាមព្រះលក្ស្មណ៍

លង់ ក. លង់គំនិត

លត់ ក. លត់ក្អួន

លុត្ត ក. លប់ពេល

លុទ្ធ ន. លុទ្ធបុគ្គល

លាប ក. លាបលន

លឺ ន. ពាក្យចិនថាអ្នក

លូក ក. លូកដៃ

លស់ ក. គ្រុនលស់,

លស់ខាន, លស់ណា

លោប ន. ការលើកពេល

លឹង ន. ពៅព្រលឹង

លលា គុ. ឆ្កួតលលា

លុង ក. លុងឈើ

លុត ក. លុតជង្គង់

លុទ្ធ ន. លុទ្ធកម្ម

លាភ ន. ខ្ញុំមានលាភ (បាន)

ឮ ក. ឮឬទេ ?

លូវ គុ. សៅហ្មង

លោះ ក. លោះស្រែពីគេ,

លោះស្លា, ជំលោះ

លោភ ន. ការចង់បានច្រើន

លិង្គ ន. (ភេទ) បុំលិង្គ

លលាដ៍ ន. លលាដ៍ក្បាល

## សទិសសព្ទក្នុងព្យញ្ជនៈ "វ"

វ ន. ឈ្មោះយានមួយ សម្រាប់ស្តេចប្រថាប់

វគ្គ ន. មួយវគ្គ

វង់ ន. ក្រុមមួយវង់, វង់មូល

វដ្ត គុ. សំសារវដ្ត (វិល)

វត្ស ន. កូនគោ

វ័ធ កិ. ក្របីវ័ធ

វា ពុ.ស. ពួកវាលេងក្មេង

វាត កិ. វាតមុខ, វាតទី

វិវិត្ត គុ. (ស្ងាត់) វិវិត្តដ្ឋាន

វារ កិ. វារហើយ ! វារ វារកកទឹកស្អុត

វាក់ កិ. ក័ន្ទប្រឡាំ, វាក់គំនិត

វង្ស ន. ព្រះរាជវង្ស

វត្ត ន. វត្តលោក, វត្តប្រតិបត្តិ

វត្សឬវត្សរ៍ ន. សតវត្ស

វាត់ កិ. វាត់សន្ទូច

វារ កិ. ក្មេងវារលេង

វាទ ន. ពាក្យពោល, ផរុស-វាទ, វិវាទគ្នា

វិវិធ គុ. (ច្រើនយ៉ាង) វិវិធ-ភ័ណ្ឌ

វិហាឬវិហាស៍ ន. ឋានសួគ៌, វិហារ ន. ព្រះវិហារ

អាកាស

វី កិ. វីគ្រាប់ស្រូវ    វីរ គុ. (ក្លាហាន) វីរបុរស

## សទិសស័ព្ទក្នុងព្យញ្ជនៈ «ស»

ស គុ. ពណ៌សខ្មៅ    ស កិ. សសេចក្តី

សរ ន. ធ្នូសរ    សរ កិ. សំដីសរជាតិ

ស័ក ន. ឯកស័ក    សក្តិ ន. អ្នកមានបណ្តាសក្តិ

សាក់ កិ. សាក់ខ្លួន    ឋានន្តរស័ក្តិ

សង់ កិ. សង់សាលា    សង្ឃ ន. ព្រះសង្ឃ

សង្ស ន. អានិសង្ស    គណៈសង្ឃ

សង្កា ន. សេចក្តីសង្ស័យ    សង្ការ ន. សង្គ្រាម

សង្ហារ កិ. (បណ្ដាល, និមិត្ត) ខ្ញុំសង្ហារឃើញខ្មោច

សង្ហារណ៍ ន. ការដឹកនាំ

សង្ហា គុ. រាងសង្ហា

សង្ហារ កិ. (សម្លាប់) សង្ហារជីវិត

សត្ត ប.សំ. ៧

សត្វ ន. ពួកសត្វ

សត្យ ន. ពាក្យសត្យ

សាត់ កិ. សាត់ទៅវិញទៅមក

សប់ កិ. សប់គង់

សប្ត, សប្តិ ន. យល់សប្តិ

សព ន. (ខ្មោច) លើកសព. សំស្ការ

សព្វ គុ. សព្វថ្ងៃ, សព្វដង សព្វគ្រប់, សព្វយ៉ាង

សម គុ. សមគ្នា

សិំ ន. គ្រឹស៊ីសំ

សម៉ ន. ដើមសម៉

សមរ ន. សមរភូមិ

សា កិ. សាចុះសាឡើង

សា ន. សាស្រូវ

សារ ន. ដំរីសារ

សារ ន. ខ្ញុំមសារ, ឯកសារ

សៅ គុ. សម្បុរសៅ

សៅរ៍ ន. ថ្ងៃសៅរ៍

សិង ក. លោកសិង(ដេក)　　សិង្ហ ន. សត្វសិង្ហ

សិត ក. សិតទឹក　　សិទ្ធ គុ. សិទ្ធកម្ម

សិរ ន ព្រះសិរ (ក្បាល)　　សេ ក. វិ. ដើរញាប់សេ

សេវ គុ. ឥតញញើត

សុក ន. ទង់សុក　　សុខ គុ. សុខសប្បាយ

សុក្រ ន. ថ្ងៃសុក្រ

សុង ន. សួយសុង　　សុង្ក ន. (ពន្ធ) សុង្កបរស

សូ ន. ខ្សែសូ　　សូរ គុ. សូរសំឡេង, សូរភាព

សូន ក. សូនរូប　　សូន្យ គុ. ស្ងាត់សូន្យ

សួ ក. សួស្ពាន　　សួរ ក. សួរឆ្លើយ

សួគ៌ ន. ឋានសួគ៌

សៀ ក. លះបង់, សៀកំឡាំង　　សៀរ ក. វិ. ដើរសៀរ

សេក ន. សេកសោម　　សេក្ខ ឬ សេខ ន. អ្នករៀន

សេត គុ. សប្បុរស    សេដ្ឋ គុ. សេដ្ឋកម្ម

សេស គុ. សេសសល់,    សេះ ន. សត្វសេះ

ថ្ងៃសេស, ពិសេស    សសេះសសោះ

សំរិត កិ. សំរិតសំរាំង    សំរឹទ្ធិ ន. ផ្ដិលសំរឹទ្ធ

សាសន៍ ន. សាសន៍តាម,    សាស្ត្រ ន. (ក្បួនច្បាប់)

ពុទ្ធសាសន៍    ភូមិសាស្ត្រ, ប្រវត្តិសាស្ត្រ

សះ កិ. ជាសះស្បើយ

ស្កា ន. ដើមស្កា    ស្ការ កិ. ពស់ស្ការគ្នា

ស្កុស គុ. សស្កុស, ស្កុសស្កាយ    ស្កុះ ន. ដើមស្កុះ

ស្រាស់ កិ. ស្រាស់បន្ទា    ស្រះ ន. ស្រះស្រង់

ស្រុស កិ. ស្រុសទឹកក្ដៅ    ស្រុះ កិ. ស្រុះស្រួលគ្នា

ស្នា ន. ស្នាក្ដី    ស្នារ កិ. ស្នារលាមោស

ស្និត ន. ចេកមួយស្និត ស្និទ្ធ កិ. ស្និទ្ធស្នាលគ្នា

ស្លេះ កិ. ស្លេះទុកសិន ស្លេស្ម ន. ក្អកធ្លាក់ស្លេស្ម

ស្នើ កិ. ស្នើការ ស្នៀរ ន. មុមួយស្នៀរ

សទិសសព្ទក្នុងព្យញ្ជនៈ «ហ»

ហត្ថ ន. (ដៃ) មួយហត្ថ ហាត់ កិ. ហាត់ប្រាណ

ហដ្ឋ ន. ហត្ថចិត្ត (រីករាយ)

ហា ឧ. សំ. ហោរហាយ(៩), ហារ កិ. លេខដើមហារ

ហាមាត់

ហៀ គុ. ស្តើងហៀ ហៀរ កិ. ទឹកហូរហៀរ

ហោ ន. ឈើគូសមួយហោ ហោរ ន. ហោរបេះទាយ

("ឡ" ឥតមានសទិសស័ព្ទទេ)

សទិសស័ព្ទក្នុងព្យញ្ជនៈ "អ"

អ ន. ប៉ុស    អរ កិ. ត្រេកអរ

អង់ កិ. រង់ចាំ, អង់ចាំ    អង្ក ន. អង្កវិទ្យា

អង្គ ន. លោកមួយអង្គ, ព្រះអង្គ

អង្គា ន. ដើមអង្គា    អង្គារ ន. ថ្ងៃអង្គារ

អត្ត ន. (ខ្លួន) អត្តឃាត    អដ្ឋ ប. សំ. ៨

អត្ថ ន. (សេចក្ដី) អត្ថប្រយោជន៍    អឌ្ឍ គុ. (កន្លះ) អឌ្ឍមាស

អាត់ គុ. សេកអាត់    អាត់ ន. អាត់ស៊ីដៃ

អន់ គុ. កំឡាំងអន់    អន្ធ គុ. (ខ្វាក់) អន្ធការ

| | |
|---|---|
| អន្ន ន. គ្រឿងបរិភោគ | អន្ត គុ. (អាក្រក់) អន្តគម្ម |
| អប្ប គុ. ស្តួចស្តើង | អ័ព្ទ, អ័ភ្រ ន. អ័ព្ទផ្សែង |
| អាប់ គុ. អាប់អួរ | អាប់ កិ. អាប់លុយ |
| អា បុ. ស. អានេះទៅណា? | អារ កិ. អារឈើ |
| អារ្យ ន. អារ្យធម៌ | អាថ៌ ន. ធម៌អាថ៌, អាថ៌កំបាំង |
| អាចារ ន. ចរិយា, មារយាទ | អាចារ្យ ន. គ្រូអាចារ្យ |
| ឥត កិ. ឥតមាន | ឥដ្ឋ ន. ផ្ទះឥដ្ឋ, ឥដ្ឋមនុញ្ញផល |
| ឥណ ន. (បំណុល) ឥណទាន | ឥន្ទ, ឥន្ទ្រ ន. ព្រះឥន្ទ |
| ឧក កិ. បន្ទោស, ឧកបត្រង្គ | អុក ន. ខ្សែអុក |
| ឧស ឬ អុស ន. ឧសដុត | អុះ! ឧ. អុះ! វិះធ្លាក់! |
| អួត កិ. (យំសោក) កុំអួតធ្វើអ្វី | អូដ្ឋ ន. សត្វអូដ្ឋ |
| អ្នក បុ. ស. មួយនាក់ | ឆាក់ សព្វ. ពីរនាក់ |

= ចប់ =

## ផ្សាយចេញពីបណ្ណាគារ ឌុប-ឈឹន ភ្នំពេញ

| | |
|---|---|
| សរសេរតាមសូត្រខ្មែរ | និពន្ធដោយ ជូ ថាន់ |
| ពង្សាវតារប្រទេសកម្ពុជា | —,,— រ.គោវេ |
| ទុំទាវ (ការសិក្សាស្រាវជ្រាវ) | —,,— គឹម.សែត |
| កុលាបប៉ៃលិន (ការសិក្សាស្រាវជ្រាវ) | —,,— —,,— |
| ហង្សយន្ត (ការសិក្សាស្រាវជ្រាវ) | —,,— —,,— |
| លេខាធិការឯកទេស | គឹម-សែត ជូ-ថាន់ |
| វិធីសម្ពន្ធខ្មែរ | យូ-ជិន |
| សិក្សាអនុពាក្យ | និពន្ធដោយ គិត-ហ៊ាន |
| ឧបករណ៍អនុពាក្យ | និពន្ធដោយ គិត-ហ៊ាន |

### សៀវភៅបំរុងនឹងចេញ

| | |
|---|---|
| ការតែងសេចក្ដី (ប្រធានសិក្សាស្រាវជ្រាវ) | គឹម-សែត |
| ការតែងសេចក្ដីខ្មែរ (ថ្នាក់បរិ. អនុ. និង មធ្យម.) | —,,— |

រោងពុម្ពវីរយៈ:

តម្លៃ ២០រ០០